# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ភូមិ ឃុំមានសុវត្ថិភាពនៅសង្កាត់បារាយណ៍
# ក្រុងដូនកែវ ខេត្តតាកែវ

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ                                      ណែនាំដោយ

និស្សិតឈ្មោះ **ហេង សុភាលី**                          លោក **គាត គា**

**សោម ពិសី**


ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ                ឆ្នាំចូលសិក្សា ២០២០

ជំនាន់ទី ១៧                                   ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ ហេង សុភាលី និងសោម ពិសី ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈជំនាន់ទី១៧នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមលំឱន កាយប្រណិប័តន៍សំដែងនូវកត្តញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក និងអ្នកម្តាយ ដែលបាន ផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយសេចក្តី មេត្តា ករុណា រហូតដល់កូនមានឱកាសបានសិក្សា រៀនសូត្រដល់ថ្ងៃបញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយលោកទាំងពីរខិតខំជម្នះរាល់ឧបសគ្គមិនខ្លាចនឿយហត់ ពុះពារឱ្យកូន បានសិក្សារៀនសូត្រមានចំណេះដឹងខ្ពង់ខ្ពស់ប្រកបដោយគន្លងធម៌។លើសពីនេះទៀតយើងខ្ញុំទាំងពីរអ្នកសូម សម្តែងនូវការដឹងគុណ ព្រមទាំងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

- ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចណ្ណា** ព្រមទាំងលោក/លោកស្រីសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រង លោក/លោកស្រីសាស្រ្តាចារ្យ និងមន្រ្តីទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទ នីតិស្រាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។
- លោក **ម៉ែន ចឹម** ជាចៅសង្កាត់បារាយណ៍ ព្រមទាំងចៅសង្កាត់រងទី១ ចៅសង្កាត់រងទី២ និងលោក **គង់ គួ** ជាស្មៀនសង្កាត់បារាយណ៍ ព្រមទាំងជំនួយការហិរញ្ញវត្ថុ និងជំនួយការរដ្ឋបាល មេភូមិ និងអនុភូមិជាដើម។

ជាពិសេសលោកគ្រូណែនាំ **គាត គា** ជាលោកគ្រូឯកទេសរដ្ឋបាលសាធារណៈនៃវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានណែនាំយើងខ្ញុំនៅក្នុងការសរសេរសារណាក្រោមប្រធានបទ៖ **ភូមិ ឃុំសុវត្ថិភាព សង្កាត់បារាយណ៍ ខេត្តតាកែវ** ដែលបានចំណាយពេលដ៏មានតម្លៃនៅក្នុងការតម្រង់ទិស អប់រំ ណែនាំ ផ្តល់ឯកសារ ព្រមទាំងបានជួយផ្តល់ជាគំនិតនៅក្នុងការសរសេរ និងត្រួតពិនិត្យកែលម្អសារណាមួយនេះយ៉ាងយកចិត្តទុកដាក់ និងទឹកចិត្តរីករាយបំផុតរហូតឈានដល់ការបញ្ចប់ប្រកបដោយជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំសូមជូនសមិទ្ធផលសារណាបញ្ចប់ឆ្នាំដែលសម្រេចមួយនេះ ជូនចំពោះលោកអ្នកមានគុណ ឯកឧត្តម និងលោកជំទាវ លោក/លោកស្រីសាស្រ្តាចារ្យបណ្ឌិតទាំងអស់ សូមទទួលយកដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងពីរនាក់។ យើងខ្ញុំសូមជូនពរដល់លោកអ្នកទាំងអស់គ្នា និងក្រុមគ្រួសារ សូមឱ្យមានសុខភាពល្អ កម្លាំងពលំមាំមួន ប្រាជ្ញាឈ្លាសវៃ ជោគជ័យគ្រប់ភារកិច្ច ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមកនេះ ធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាល។ នៅពេលចាប់ផ្តើមសិក្សាដំបូងយើងខ្ញុំមានក្តីស្រមៃចង់បន្សល់ទុកនូវស្នាដៃមួយនៅសាកលវិទ្យាល័យបន្ទាប់ពីបានបញ្ចប់ការសិក្សា ដើម្បីទុកជាឯកសារសម្រាប់ជួយដល់សិស្សនិស្សិតក្នុងការសិក្សាស្រាវជ្រាវនាពេលក្រោយៗទៀត។ ស្ថិតនៅក្នុងការសិក្សានាពេលដំបូង យើងខ្ញុំបានជួបប្រទះនៅការលំបាកមួយចំនួនដោយសារតែជំនាញនេះត្រូវបានផ្លាស់ប្តូរនូវមុខវិជ្ជាថ្មីៗមួយចំនួន ហើយម្យ៉ាងវិញទៀតគឺឯកសារដែលទាក់ទងនឹងមុខវិជ្ជាមួយចំនួនមិនសូវសម្បូរបែបនោះទេ ពោលគឺការសិក្សា និងឯកសារភាគច្រើនត្រូវបានសាស្រ្តាចារ្យពឹងផ្អែកទៅលើឯកសារបរទេសច្រើនជាងឯកសារក្នុងស្រុក ដែលជាហេតុធ្វើឱ្យចំណុចមួយចំនួនមានការលំបាកក្នុងការស្វែងយល់។ ប៉ុន្តែទោះជាយ៉ាងណាក្តី ដោយសារតែការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងរបស់យើងខ្ញុំ បូករួមទាំងការបង្ហាត់បង្ហាញពីសំណាក់សាស្រ្តាចារ្យផងនោះ ទើបធ្វើឱ្យយើងខ្ញុំទទួលបានលទ្ធផលល្អជាទីគាប់ចិត្ត ស្តែងឡើងតាមរយៈលទ្ធផលនេះបានបង្ហាញថាយើងខ្ញុំបានទទួលនូវឱកាសមួយនៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

នៅពេលទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សា យើងខ្ញុំក៏បានសម្រេចចិត្តជ្រើសរើសប្រធានបទ " ភូមិ ឃុំមានសុវត្ថិភាព នៅសង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ " ដើម្បីធ្វើការសិក្សាស្រាវជ្រាវ។ មូលហេតុសំខាន់ដែលទាក់ទាញចិត្តរបស់យើងខ្ញុំឱ្យជ្រើសរើសប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ គឺដោយសារតែគោលនយោបាយនេះត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១០ ប៉ុន្តែទើបតែប៉ុន្មានឆ្នាំនេះត្រូវបានសម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ឱ្យពង្រឹងជាថ្មីម្តងទៀត ម្យ៉ាងទៀតក៏ជាប្រធានបទថ្មីមួយ ដែលនិស្សិតទាំងអស់មិនសូវបានលើកយកមកសិក្សាស្រាវជ្រាវផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថាស្នាដៃមួយនេះអាចទុកធ្វើជាទុនដល់ការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងការរៀបចំសណ្តាប់ធ្នាប់តាមភូមិ ឃុំ និងអភិវឌ្ឍន៍ឱ្យបានកាន់តែរីកចម្រើនរបស់និស្សិតជំនាន់ក្រោយៗទៀត។ រាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនា នូវពាក្យពេចន៍ក៏ដូចជាអត្ថន័យសូមមេត្តាខន្តីអភ័យទោស។ សូមស្វាគមន៍ជានិច្ចនូវរាល់ការរិះគន់ទាំងឡាយណា ដែលធ្វើឡើងក្នុងគោលបំណងស្ថាបនា ដើម្បីឱ្យស្នាដៃមួយនេះកាន់តែមានភាពល្អត្រឹមត្រូវនិងប្រសើរជាងនេះ។

# ការឧទ្ទិសស្នាដៃ

យើងខ្ញុំសូមឧទ្ទិសស្នាដៃដែលកើតឡើងពីការសិក្សាស្រាវជ្រាវលើប្រធានបទ៖ **ភូមិ ឃុំសុវត្ថិភាព សង្កាត់បារាយណ៍ ខេត្តតាកែវ** ជូនចំពោះ៖

- ជីដូន ជីតា ញាតិការទាំងប្រាំពីរសន្តាន និងអ្នកមានគុណដែលបានជួយជ្រោមជ្រែងកន្លងមក។
- អ្នកប្រាជ្ញ បញ្ញវន្តខ្មែរ ដែលបានបូជាកម្លាំងកាយចិត្ត និងទ្រព្យធនធាននៅក្នុងការការពារ ចងក្រងឯកសារ អក្សរសាស្ត្រទុកជាមរតកសម្រាប់កូនខ្មែរជំនាន់ក្រោយ។ សូមមនសិការជាតិខ្មែរ ស្ថិតនៅជាប់ជានិច្ចក្នុងដួងប្រលឹងប្រជារាស្ត្រខ្មែរ។
- ប្រជារាស្ត្រខ្មែរគ្រប់ជំនាន់  និងគ្រប់រូបដែលបានខិតខំធ្វើពលិកម្មគ្រប់បែបយ៉ាង  នៅក្នុងការការពារប្រទេសជាតិ និងអភិវឌ្ឍន៍មាតុភូមិប្រទេសជាតិខ្មែរយើងឱ្យបានរស់រានរហូតដល់ពេលបច្ចុប្បន្ន និងរួចផុតពីការឈ្លានពានរបស់បរទេស។
- សូមឲព្រះរាជាណាចក្រកម្ពុជាមានសុខសន្តិភាព សុវត្ថិភាពជាយូរអង្វែងដរាបរៀងទៅ។
- សូមឱ្យមានឯករាជ្យជាតិខ្មែរ បូរណភាពទឹកដី កាន់តែរឹងមាំពីមួយថ្ងៃទៅមួយថ្ងៃ សូមឱ្យកូនខ្មែរគ្រប់រូប និងគ្រប់សម័យកាលខិតខំរៀនសូត្រដើម្បីអនាគត គ្រួសារ និងមាតុប្រទេសជាតិរបស់យើងទាំងអស់គ្នា។

# មាតិកា

**សេចក្តីផ្តើម** ............ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១

២. ចំណោទបញ្ហា ............ ២

៣. គោលបំណង ............ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ............ ៣

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ............ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៤

**ជំពូកទី១ សញ្ញាណទូទៅនៃភូមិ ឃុំ សុវត្ថិភាព** ............ ៥

**១.គោលបំណង និងសំណួរមពរ** ............ ៥

**១.១ តួនាទី និងភារកិច្ច** ............ ៥

**១.១.១ ក្រុមប្រឹក្សា** ............ ៦

**១.១.២ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់** ............ ៦

**១.១.៣ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់** ............ ៦

**១.១.៤ មេឃុំ ចៅសង្កាត់** ............ ៦

**១.១.៥ ជំទប់ទី១ ចៅសង្កាត់ទី១** ............ ៧

**១.១.៦ ជំទប់ទី២ ចៅសង្កាត់រងទី២** ............ ៧

**១.១.៧ គណៈកម្មាធិការ** ............ ៧

**១.១.៨ ស្មៀន** ............ ៨

**១.១.៩ ប៉ុស្តិ៍លិកឃុំ សង្កាត់** ............ ៩

១.១.១០ មេភូមិ និងជំនួយការមេភូមិ ........................................................ ៩

១.២ សមាសភាពអ្នកចូលរួម ........................................................ ១២

១.៣ នីតិវិធីក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ........................................................ ១៥

១.៤ កម្លាំងប្រជាការពារសន្តាត់បារាយណ៍ ........................................................ ១៥

ជំពូកទី២៖ ដំណើរការគ្រប់គ្រង និងការប្រព្រឹត្តទៅរបស់សន្តាត់បារាយណ៍ ........................................................ ១៧

២.លក្ខណៈសម្បត្តិ ភូមិ ឃុំ សុវត្ថិភាព ........................................................ ១៧

២.១ វិធានការមូលដ្ឋាន ........................................................ ១៧

ជំពូកទី៣ ៖ ផែនការសន្តាត់បារាយណ៍ និងកម្មវិធីវិនិយោគ ........................................................ ២៣

៣.ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច ........................................................ ២៤

៣.១.១ ស្ថានភាពភូមិសាស្ត្រ ........................................................ ២៤

៣.១.២ ផែនការណ៍ឃុំ ឬ ការវិនិយោគថវិកាឃុំ ........................................................ ២៥

៣.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ........................................................ ២៦

៣.២.១ ផ្នែកសេដ្ឋកិច្ច ........................................................ ២៦

៣.២.២ផ្នែកសង្គមកិច្ច ........................................................ ២៧

៣.២.២.១ វិស័យអប់រំ ........................................................ ២៧

៣.២.២.២ វិស័យសុខាភិបាល ........................................................ ២៨

៣.២.២.៣ ការងារយេនឌ័រ ........................................................ ២៨

៣.២.២.៤ ការងារសាសនា ........................................................ ២៨

៣.២.២.៥ ការងារអន្តោប្រវេសន៍ និងការផ្លាស់ប្តូរលំនៅ ........................................................ ២៩

៣.២.២.៦ ពិការភាព និងភាពងាយរងគ្រោះ ........................................................ ២៩

៣.២.៣ ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ........................................................ ៣០

**៣.៣ ការតាមដាននិងវាយតម្លៃ ការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំ** ........................................ ៣១

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៣៩

**អនុសាសន៍** ................................................................................................................ ៤០

**ឯកសារយោង**

**ឧបសម្ព័ន្ធទី១**

**ឧបសម្ព័ន្ធទី២**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ត្រូវបានគេទទួលស្គាល់ថាជាប្រទេសដែលមានប្រវត្តិសាស្ត្រយូរអង្វែងប្រកបដោយមោទនភាពជាទីចាប់ចិត្តយ៉ាងក្រៃលែង។ សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀតមានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុត្តិសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រដ្ឋាភិបាលកម្ពុជា។ ទោះបីជាយើងមានសន្តិភាពស្ថិរភាពយ៉ាងរឹងមាំពិតមែន ប៉ុន្តែសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខុមាលភាពប្រជាពលរដ្ឋ និងការផ្តល់សេវាសាធារណៈចាំបាច់នានា នៅតែជាបញ្ហាអទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឱ្យជនគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។

ឆ្លងកាត់តាមបទពិសោធន៍អស់រយៈពេល១០ឆ្នាំ ក្រសួងមហាផ្ទៃដោយមានការគាំទ្រ និងចូលរួមពីក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងាររបស់រដ្ឋាភិបាលចុះតាមមូលដ្ឋាន ជាមួយអ្នកពាក់ព័ន្ធបានចាត់តាំងអនុវត្តប្រកបដោយជោគជ័យ និងបានធ្វើការកែលម្អផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ **ភូមិឃុំ មានសុវត្ថិភាព** ជាបន្តបន្ទាប់ឱ្យស្របតាមបរិបទនៃការរីកចម្រើនរបស់សង្គមជាតិ។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន និងឱ្យមានការចូលរួមគាំទ្រកាន់តែចម្រើនថែមទៀតរាជរដ្ឋាភិបាលបានសម្រេចកែលម្អលក្ខណៈសម្បត្តិនៃគោលនយោបាយ **ភូមិឃុំសង្កាត់មានសុវត្ថិភាព** ព្រមទាំងកម្រិតគោលនយោបាយ ដែលមានគោលបំណងដូចជា

១. បន្តកសាង និងពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងមានការលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

២. កសាងបានជាកម្លាំងសរុប វិធានសរុប និងមធ្យោបាយសរុបក្នុងការអនុវត្តគោលនយោបាយ "ភូមិ ឃុំសុវត្ថិភាព" ដោយបំផុសឱ្យមានកិច្ចសហប្រតិបត្តិការចូលរួមជាមួយសមត្ថកិច្ចវិស័យសាធារណៈ វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋទូទាំងប្រទេស។

មិនត្រឹមតែប៉ុណ្ណោះ ភូមិ ឃុំ នៅសង្កាត់បារាយណ៍ក៏ដូចគ្នាផងដែរ គឺកំពុងតែមានការពង្រឹងសុវត្ថិភាពយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋនៅ ភូមិ ឃុំ ដើម្បីឱ្យមានការកាត់បន្ថយពីគ្រោះមហន្តរាយផ្សេងៗដែលបណ្តាលមកពីមនុស្ស គ្រោះធម្មជាតិ ជំងឺរាតត្បាតផ្សេងៗព្រមទាំងមានការពង្រឹង និងលើកកម្ពស់អនាម័យ និងបរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋគួរឱ្យកត់សម្គាល់ផងដែរ។

## ២. ចំណោទបញ្ហា

ដូចដែលយើងបានដឹងរួចមកហើយថា ការងារគ្រប់គ្រង ភូមិ ឃុំសង្កាត់ឱ្យមានសុវត្ថិភាពល្អគឺជាតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំយ៉ាងណាឱ្យប្រជាពលរដ្ឋរស់នៅងាយស្រួល មិនព្រួយបារម្ភរឿងគ្រោះថ្នាក់ចោរកម្ម ឬ ការចលាចលផ្សេងៗដែលកើតចេញពីក្មេងទំនើង។ ជាក់ស្តែងនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវការកែលម្អបន្ថែម អាស្រ័យហេតុនេះហើយទើបក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ ភូមិ ឃុំ សង្កាត់សុវត្ថិភាពបានបង្ហាញនូវចំណោទបញ្ហាដូចខាងក្រោម៖

១. តើដំណើរការនៃការគ្រប់គ្រងភូមិ ឃុំ សង្កាត់សុវត្ថិភាពមានការប្រព្រឹត្តដូចម្តេច?

២. តើការគ្រប់គ្រងភូមិ ឃុំ សង្កាត់ សុវត្ថិភាពជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ? និងមានដំណោះស្រាយយ៉ាងដូចម្តេច?

## ៣. គោលបំណង

គោលបំណងក្នុងការស្រាវជ្រាវប្រធានបទ ភូមិ ឃុំ សុវត្ថិភាព នៅបារាយណ៍ គឺដើម្បីស្វែងយល់ពីចំណុចសំខាន់នៃវិធីសាស្ត្រក្នុងការដឹកនាំ គ្រប់គ្រង និងការអភិវឌ្ឍន៍ កែលម្អឱ្យរីកចម្រើននូវសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋនៅសង្កាត់បារាយណ៍ ព្រមទាំងគ្រោះមហន្តរាយ និងជំងឺរាតត្បាតផ្សេងៗព្រមទាំងធ្វើការរួមចំណែកកែលម្អទៅលើចំណុចខ្វះខាតនានាដែលតែងតែកើតឡើងជាយថាហេតុ។ មិនត្រឹមតែប៉ុណ្ណោះ បានបន្សល់ទុកជាស្នាដៃសម្រាប់និស្សិតជំនាន់ក្រោយ ដើម្បីបានសិក្សាស្វែងយល់ ទុកជាឯកសារសម្រាប់ចែករំលែកបន្ត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ទំហំនៃការស្រាវជ្រាវនេះ វាមានទំនាក់ទំនងជាមួយ ឃុំ សង្កាត់ ជាពិសេសសង្កាត់បារាយណ៍ដែលស្ថិតនៅក្នុងខេត្តតាកែវ និងកាតាព្វកិច្ចដោះស្រាយរាល់បញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងសុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ និងសុខុមាលភាពប្រជាពលរដ្ឋ និងកែលម្អនូវប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនានាក្នុងសង្កាត់បារាយណ៍ ខេត្តតាកែវ។

ដោយសារប្រធានបទខាងលើមានភាពស៊ីជម្រៅផ្សាភ្ជាប់នឹងការគ្រប់គ្រងសណ្ដាប់ធ្នាប់សន្តិសុខ ការពារឃុំ សង្កាត់ពីគ្រោះមហន្តរាយនានា ដែលបង្កឡើងដោយក្មេងទំនើង ជំងឺរាតត្បាត ឬ គ្រោះធម្មជាតិជាដើម។ ដូចនេះខ្លឹមសារនៃប្រធានបទនេះផ្ដោតសំខាន់លើ៖

ទី១. ទាក់ទងនឹងបទដ្ឋានគតិយុត្តិ ឬ វិធានគតិយុត្តិដែលទាក់ទងនឹងការគ្រប់គ្រងសុវត្ថិភាពឃុំ សង្កាត់

ទី២. ទាក់ទងនឹងការអនុវត្ត អន្តរាគមន៍ក្នុងឃុំ សង្កាត់ពេលជួបបញ្ហា

ទី៣. ពិភាក្សាលើប្រធានបទដែលស្រាវជ្រាវ

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃការស្រាវជ្រាវនេះ នឹងចូលរួមជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការសិក្សាស្រាវជ្រាវរបស់បងប្អូនមិត្តនិស្សិត ក៏ដូចជាការចូលរួមជាវិភាគទាន នៅក្នុងការចែករំលែកពុទ្ធិជូនដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងការយល់ដឹងបន្ថែមទៀតពាក់ព័ន្ធនឹងភូមិ ឃុំសុវត្ថិភាពនៅសង្កាត់បារាយណ៍ ខេត្តតាកែវ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ទិន្នន័យដែលបានស្រាវជ្រាវ គឺយកមកវិភាគតាមរយៈការពិពណ៌នាបែបគុណភាព ដើម្បីទទួលបាននូវលទ្ធផលនៃការស្រាវជ្រាវនេះមានលក្ខណៈវិទ្យាសាស្ត្រ និងកម្រិតនៃការជឿជាក់អាចទទួលយកបាន ដោយប្រើទិន្នន័យទីមួយ (Primary Data) និងទិន្នន័យទីពីរ ( Secondary Data) បូករួមបញ្ចូលគ្នា។

**ទិន្នន័យទីមួយ** ជាប្រភេទទិន្នន័យផ្ទាល់ (Primary Data) ការប្រមូលផ្ដុំឯកសារតាមរយៈការស្វែងចេញតាមរូបភាពជាច្រើនដូចជាការចុះស្រាវជ្រាវ ការធ្វើកិច្ចសម្ភាសន៍ទៅកាន់មេឃុំ ចៅសង្កាត់ ស្មៀន មេប៉ុស្តិ៍នគរបាល និងមន្ត្រីដែលពាក់ព័ន្ធដទៃទៀតអំពី ដំណើរការ និងបញ្ហាមួយចំនួននៅពេលអនុវត្តគោលនយោបាយភូមិ ឃុំសុវត្ថិភាព ដោយគោលបំណងទទួលបានព័ត៌មានច្បាស់លាស់ និងជាក់ស្ដែង។

**ទិន្នន័យទីពីរ** (Secondary Data) ជាទិន្នន័យដែលទទួលបានតាមរយៈការស្វែងយល់ពីបណ្ដា ឯកសារនានា និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធដូចជា គោលនយោបាយភូមិ ឃុំសុវត្ថិភាពសង្កាត់បារាយណ៍។ ច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។ សេចក្ដីប្រកាសរបស់ក្រសួងមហាផ្ទៃ ស្ដីពីតួនាទីទៅភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់។ គោលនយោបាយប្រាំឆ្នាំរំកិលរបស់សង្កាត់បារាយណ៍ពីឆ្នាំ២០២៣ ដល់២០២៧។ ផែនការអភិវឌ្ឍបីឆ្នាំរំកិលរបស់សង្កាត់បារាយណ៍ពីឆ្នាំ២០២៣ ដល់២០២៥ និងផែនការថវិការបស់សង្កាត់បារាយណ៍ក្រុងដូនកែវឆ្នាំ២០២៣។ តាមរយៈ Google Website YouTube ជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ចែកចេញជា **៣**ជំពូកគឺ៖

**ជំពូកទី១៖** សញ្ញាណទូទៅនៃភូមិ ឃុំ សុវត្ថិភាព គោលបំណង និងសំណូមពរ តួនាទីនិងភារកិច្ច សមាសភាពអ្នកចូលរួម នីតិវិធីនៅក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព កម្លាំងប្រជាការពារសង្កាត់បារាយណ៍។

**ជំពូកទី២៖** ដំណើរការគ្រប់គ្រងនិងប្រព្រឹត្តទៅរបស់សង្កាត់បារាយណ៍ លក្ខណៈសម្បត្តិភូមិ ឃុំសុវត្ថិភាព វិធានការមូលដ្ឋាន និងការចាត់តាំងអនុវត្ត។

**ជំពូកទី៣៖** ផែនការសង្កាត់បារាយណ៍ និងកម្មវិធីវិនិយោគ ស្ថានភាពសេដ្ឋកិច្ចសង្គម សេចក្តីសង្ខេបទិន្នន័យចម្បងក្នុងឃុំ ស្ថានភាពភូមិសាស្ត្រ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច អប់រំ សុខាភិបាល យេនឌ័រ សាសនា ការងារអន្តោប្រវេសន៍ និងផ្លាស់ប្តូរលំនៅ ពិការភាព និងភាពងាយរងគ្រោះ ផ្នែកគ្រប់គ្រងធម្មជាតិ បរិស្ថាន និងប្រែប្រួលអាកាសធាតុ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំ។

# ជំពូកទី១
# សញ្ញាណទូទៅនៃភូមិ ឃុំ សង្កាត់

## ១.គោលបំណង និងសំណួរមពរ

### ១.១ តួនាទី និងភារកិច្ច

ខាងក្រោមនេះ គឺជាគំនូសបំព្រួញនៃរចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់។ ដោយឡែក តួនាទី ភារកិច្ចជាក់លាក់របស់អង្គនីមួយៗមានចែងដូចខាងក្រោម៖



### ១.១.១ ក្រុមប្រឹក្សា[1]

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញការងាររបស់ខ្លួនតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់។ កិច្ចប្រជុំក្រុមប្រឹក្សា ត្រូវធ្វើការពិនិត្យ ពិភាក្សា និងអនុម័តលើកិច្ចនានាពាក់ព័ន្ធនឹងការអនុវត្តមុខងារ និងអំណាចរបស់ក្រុមប្រឹក្សា។

ជាមួយគ្នានេះមុនចាប់ផ្តើមការងារក្រុមប្រឹក្សាសង្កាត់នីមួយៗត្រូវរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសម្រាប់អង្គប្រជុំ និងរបៀបរបបធ្វើការងាររបស់ក្រុមប្រឹក្សា។ ខ្លឹមសារគោល និងបែបបទនីតិវិធីក្នុងការរៀបចំបទបញ្ជាផ្ទៃក្នុងចំពោះនីតិវិធីនៃការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា។

### ១.១.២ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់

- ធ្វើជាអធិបតីក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់
- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងតិច១ដង ក្នុង១ខែ
- ធានាកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

### ១.១.៣ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់

- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាច តួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយពលរដ្ឋ

### ១.១.៤ មេឃុំ ចៅសង្កាត់[2]

- មានសិទ្ធិចុះហត្ថលេខាលើដីកា និងសេចក្តីសម្រេចរបស់ឃុំ សង្កាត់របស់ខ្លួន
- មានសិទ្ធិតែងតាំងគណៈកម្មាធិការ ជំនួយការនានាតាមការចាំបាច់ដើម្បីផ្តល់យោបល់ឱ្យខ្លួន
- មានសិទ្ធិចុះហត្ថលេខាលើលិខិតស្នើសុំសេវារដ្ឋបាលឃុំ សង្កាត់របស់ខ្លួន
- ធានាថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត

[1] ដកស្រង់ចេញពី ជំពូកទី២អំពីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១

[2] ដកស្រង់ចេញពី ជំពូកទី៣អំពីរចនាសម្ព័ន្ធឃុំ សង្កាត់ក្នុងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១

- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកាហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានានុក្រមពេលខ្លួនអវត្តមាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់មេឃុំ ចៅសង្កាត់។

### ១.១.៥ ជំទប់ទី១ ចៅសង្កាត់ទី១

- ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទៅ ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមាន
- នៅពេលទទួលស្តីទី មិនអាចផ្ទេរឱ្យទៅជំទប់ទី២ចៅសង្កាត់ទី២បានឡើយ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

### ១.១.៦ ជំទប់ទី២ ចៅសង្កាត់រងទី២

- ជួយមេឃុំ ចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ចៅសង្កាត់រងទី១អវត្តមាន
- នៅពេលទទួលស្តីទី មិនអាចផ្ទេរបន្តបានឡើយ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

### ១.១.៧ គណៈកម្មាធិការ

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មការនានា ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់មួយ។ គណៈកម្មាធិការនីមួយៗមានសមាជិកយ៉ាងតិច ០៣នាក់។ តួនាទីភារកិច្ចរួមរបស់គណៈកម្មាធិការនានា មានដូចខាងក្រោម៖

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជាការកសាងផែនការ និងថវិកា

- រាយការណ៍អំពីការវិវត្តន៍ការងារប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់ពីវិធានការត្រូវអនុវត្ត ដែលពាក់ព័ន្ធនឹងការងារជាសម្ថតកិច្ចរបស់ខ្លួន

បច្ចុប្បន្នរដ្ឋបាលឃុំ សង្កាត់មានគណៈកម្មការជាកាតាព្វកិច្ចចំនួន ០៣គឺ គណៈកម្មាធិការកសាងផែនការ និងថវិកា គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងគណៈកម្មាធិការលទ្ធកម្ម។

ចំពោះការរៀបចំសមាសភាព តួនាទី ភារកិច្ច និងរបៀបរបបការងារជាក់លាក់របស់ គណៈកម្មាធិការនីមួយៗសូមមើលឯកសារដូចខាងក្រោម៖

- ប្រកាសលេខ៣៨៤០ ប្រក ចុះថ្ងៃទី២២ កញ្ញា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។
- ប្រកាសណែនាំលេខ២៣១ ស.ហ.វ.ប្រក ចុះថ្ងៃទី២៩ មេសា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ស្តីពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់។

### **១.១.៨ ស្មៀន**

បុគ្គលិកក្របខណ្ឌនៅរដ្ឋបាលឃុំ សង្កាត់មានតែម្នាក់គត់គឺស្មៀនឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់គឺជាបុគ្គលិកស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលស៊ីវិលរបស់ក្រសួងមហាផ្ទៃ និងត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីបំពេញការងារជាមួយរដ្ឋបាលឃុំ សង្កាត់ ក្នុងឋានៈជាស្មៀនឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់មានតួនាទី ភារកិច្ចដូចខាងក្រោម[3]៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងគណៈកម្មការនានាបំពេញតួនាទីនិងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់
- បំពេញការងាររដ្ឋបាល
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ស្របទៅនឹងលក្ខខណ្ឌច្បាប់

[3]ភារកិច្ចជាច្រើនទៀតរបស់ស្មៀនឃុំ សង្កាត់ត្រូវបានកំណត់នៅក្នុងប្រកាសលេខ១៣២៩ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង គណៈកម្មាធិការនានារបស់ឃុំ សង្កាត់
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការ លើកលែងតែទទួលការអនុញ្ញាតឱ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឱ្យមានក្ដារខៀនព័ត៌មានមួយ ឬច្រើនកន្លែងដើម្បីបិទផ្សាយសេចក្ដីជូនដំណឹង សេចក្ដីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់សម្រាប់ឱ្យសាធារណៈជនទូទៅបានដឹងព័ត៌មានទាំងនោះ។

### ១.១.៩ បុគ្គលិកឃុំ សង្កាត់

ក្រៅពីស្មៀនឃុំ សង្កាត់មាត្រា២៩នៃច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា ៉ឃុំសង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្ដីត្រូវការ តាមការចាំបាច់នៃការងារ និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិបន្ទាប់៉។

បែបបទនៃការជ្រើសរើសបុគ្គលិកឃុំ សង្កាត់ សូមមើលសេចក្ដីណែនាំលេខ០៥៥ ស.ណ.ន ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្ដីពីនីតិវិធីនៃការជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ និងប្រកាសអន្តរក្រសួងលេខ០០២ សហវ.ប្រក ស្ដីពីការជ្រើសរើស និងការកំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។

### ១.១.១០ មេភូមិ និងជំនួយការមេភូមិ

ភូមិនីមួយៗត្រូវមានមេភូមិ និងជំនួយការចំនួន០២រូប ដែលម្នាក់អនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកភូមិ។ មេភូមិ អនុប្រធាន និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ។ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងមុខតំណែង ត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មីមកជំនួស។

ករណីមានតម្រូវការជ្រើសរើសសមាសភាពណាមួយ ក្រុមប្រឹក្សាត្រូវចាត់ចែងជ្រើសរើសសមាសភាពនោះទៅតាមនីតិវិធី និងបែបបទដូចមានចែងនៅក្នុងសេចក្ដីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃស្ដីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិ។

**ខាងក្រោមនេះ ជាតួនាទី ភារកិច្ចរបស់មេភូមិ និងជំនួយការភូមិ៖**

**ក.មេភូមិ**

- ទទួលខុសត្រូវក្នុងភូមិរបស់ខ្លួន
- តំណាងឱ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាភូមិ សង្កាត់
- បង្កើនការពីគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ នៅពេលដែលក្រុមប្រឹក្សាឃុំសង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការ ដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទិ៍៖
  - ➢ ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីតម្រូវការនិងផលប្រយោជន៍របស់ភូមិ
  - ➢ ផ្តល់ដល់ក្រុមប្រឹក្សាឃុំសង្កាត់អំពីរបៀបបង្កើន និងកសាងសមត្ថភាព ព្រមទាំងធនធានរបស់ភូមិ
  - ➢ ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសង្កាត់អំពី៖
    - + តម្រូវការនិងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូនក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
    - + ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
    - + ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន។
- ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវធានាព័ត៌មានជាឯកសារជាសាធារណៈ ដែលពាក់ព័ន្ធរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន។ឯកសារព័ត៌មានទាំងនោះ អាចរួមមានព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់
- ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

បញ្ជាក់៖

- មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងមានភូមិបានឡើយ។
- មេភូមិក៏មានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃបានឡើយ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ដោយបុគ្គល ឬគណៈកម្មាធិការ ឬអង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ។

## ខ.ជំនួយការមេភូមិ

- អនុប្រធានភូមិ ទទួលការងារជំនួសក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជាមានជំងឺ ឬមានបេសកកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពី១ថ្ងៃ។ ក្រៅពីនេះ អនុប្រធាននៅភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍនានា ក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់។
- សមាជិកភូមិ ទទួលជួយធ្វើលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ កាតចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ។

បញ្ជាក់៖ ក្រៅពីការងារខាងលើនេះមេភូមិអាចធ្វើការបែងចែក ឬប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់។

## ១.២ សមាសភាពអ្នកចូលរួម

បញ្ជីឈ្មោះក្រុមប្រឹក្សាសង្កាត់និងភូមិ នៃសង្កាត់បារាយណ៍ ក្រុងដូនកែវរួមមានដូចជា[4]៖

- សមាសភាពក្រុមប្រឹក្សាសង្កាត់

| ល.រ | គោត្តនាម នាម | ភេទ | មុខងារ | ភូមិ/អត្តភាព | លេខទូរសព្ទ |
|---|---|---|---|---|---|
| ១ | ម៉ែន ចឹម | ប្រុស | ចៅសង្កាត់ | សង្កាត់បារាយណ៍ | ០១២២៩១៧០៣ |
| ២ | ជឹង ធី | ប្រុស | ចៅសង្កាត់រងទី១ | សង្កាត់បារាយណ៍ | ០៧១៥០០២៨៨៣ |
| ៣ | រឿង ជឿន | ប្រុស | ចៅសង្កាត់រងទី២ | សង្កាត់បារាយណ៍ | ០៨៧៨៧៧៧០៣ |
| ៤ | ស្វាយ ចិន្តា | ស្រី | សមាជិកក្រុមប្រឹក្សា | សង្កាត់បារាយណ៍ | ០១៧៨៨១២០៣ |
| ៥ | អេង អៀក | ប្រុស | សមាជិកក្រុមប្រឹក្សា | សង្កាត់បារាយណ៍ | ០៩៦៩៧៧៤៨៥៥ |
| ៦ | ម៉ូវ ឡេង | ប្រុស | សមាជិកក្រុមប្រឹក្សា | សង្កាត់បារាយណ៍ | ០៧៧៨៣៨៣១៣ |
| ៧ | អ៊ុំ សុភឿន | ប្រុស | សមាជិកក្រុមប្រឹក្សា | សង្កាត់បារាយណ៍ | ០៨៨២៣១៧៦៦ |
| ៨ | ទុំ ចម្រើន | ប្រុស | សមាជិកក្រុមប្រឹក្សា | សង្កាត់បារាយណ៍ | ០១៦៩៥៨៥១៧ |
| ៩ | ញឹវ សារឿន | ប្រុស | សមាជិកក្រុមប្រឹក្សា | សង្កាត់បារាយណ៍ | ០៩៦២៣១៦០៣៦ |

[4] ដកស្រង់ចេញពី បញ្ជីឈ្មោះក្រុមប្រឹក្សាសង្កាត់ និងភូមិ នៃសង្កាត់បារាណ៍ក្រុងដូនកែវ ខេត្តតាកែវឆ្នាំ២០២៤

- សមាសភាពមន្ត្រីផ្នែករដ្ឋបាលសង្កាត់

| | | | | | |
|---|---|---|---|---|---|
| ១ | គង់ គូ | ប្រុស | ស្មៀនសង្កាត់ | សង្កាត់បារាយណ៍ | ០៩៦៤៦៣០០២៧ |
| ២ | គួន កែវនាថ | ស្រី | ជំនួយការហិរញ្ញវត្ថុ | សង្កាត់បារាយណ៍ | ០១៧៧៥៦៦៧៩ |
| ៣ | ហ៊ុយ វិបុល | ស្រី | ជំនួយការរដ្ឋបាល | សង្កាត់បារាយណ៍ | ០៧០៤៣៥៧២៧ |
| ៤ | អ៊្លឹង សាម៉ែ | ប្រុស | ជំនួយការរដ្ឋបាល | សង្កាត់បារាយណ៍ | ០៩៦៤៥៨៩៨៩៩ |

- សមាសភាពមន្ត្រីភូមិ

| | | | | | |
|---|---|---|---|---|---|
| ១ | សេង វណ្ណី | ប្រុស | មេភូមិ | ចុងថ្នល់ | |
| ២ | ហង់ បំពេញ | ស្រី | អនុភូមិ | ចុងថ្នល់ | |
| ៣ | យើ ទត | ប្រុស | សមាជិកភូមិ | ចុងថ្នល់ | |
| ៤ | សេង ម៉ាច | ប្រុស | មេភូមិ | ត្រពាំងលាក់ | |
| ៥ | អ៊ុំ ឡៃ | ស្រី | អនុភូមិ | ត្រពាំងលាក់ | |
| ៦ | រត្ន័ សុភាព | ប្រុស | សមាជិកភូមិ | ត្រពាំងលាក់ | |
| ៧ | ទិត សុខ | ប្រុស | មេភូមិ | ត្រពាំងឬស្សី | |
| ៨ | ប្រាក់ ប៊ុនធឿន | ប្រុស | អនុភូមិ | ត្រពាំងឬស្សី | |
| ៩ | ភិន សុភាព | ស្រី | សមាជិកភូមិ | ត្រពាំងឬស្សី | |
| ១០ | អ៊ីង ជា | ប្រុស | មេភូមិ | ជ្រោយសំរោង | |
| ១១ | ង៉ែត សឿន | ប្រុស | អនុភូមិ | ជ្រោយសំរោង | |
| ១២ | តែម ភឿន | ស្រី | សមាជិកភូមិ | ជ្រោយសំរោង | |
| ១៣ | គួយ ម៉ាច | ប្រុស | មេភូមិ | ឬស្សី | |
| ១៤ | សួស វ៉ាន់ណារ | ស្រី | អនុភូមិ | ឬស្សី | |
| ១៥ | ឃឹម ស៊ីធឿន | ប្រុស | សមាជិកភូមិ | ឬស្សី | |
| ១៦ | ហេង សន | ប្រុស | មេភូមិ | ក្រចាប់ | |

| | | | | | |
|---|---|---|---|---|---|
| ១៧ | យ៉ែម ចំរើន | ប្រុស | អនុភូមិ | ក្រចាប់ | |
| ១៨ | នាង សូនី | ស្រី | សមាជិកភូមិ | ក្រចាប់ | |
| ១៩ | រ៉ិត យ៉ន | ប្រុស | មេភូមិ | ខាន់ ខាវ | |
| ២០ | វង ប៊ុនធឿន | ប្រុស | អនុភូមិ | ខាន់ ខាវ | |
| ២១ | លីម វណ្ណៈ | ស្រី | សមាជិកភូមិ | ខាន់ ខាវ | |
| ២២ | ជុំ វ៉ៃ | ប្រុស | មេភូមិ | ក្រាំង តាពូង | |
| ២៣ | លុយ ផល្លី | ប្រុស | អនុភូមិ | ក្រាំង តាពូង | |
| ២៤ | ឌុក គន្ធា | ស្រី | សមាជិកភូមិ | ក្រាំង តាពូង | |
| ២៥ | មាសផាន | ប្រុស | មេភូមិ | ស្វាយ ជ្រំ | |
| ២៦ | ផាញ សៅ | ប្រុស | អនុភូមិ | ស្វាយ ជ្រំ | |
| ២៧ | អ៊ុង សារ៉ាត | ស្រី | សមាជិកភូមិ | ស្វាយ ជ្រំ | |
| ២៨ | ថាន់ ទឹក | ប្រុស | មេភូមិ | ដូន ពែង | |
| ២៩ | ទេព ម៉េង | ស្រី | អនុភូមិ | ដូន ពែង | |
| ៣០ | ស៊ិន ហ៊ួន | ប្រុស | សមាជិកភូមិ | ដូន ពែង | |
| ៣១ | យឹម សារឹម | ស្រី | មេភូមិ | ស្វាយ ឬស្សី | |
| ៣២ | ញ៉េប ខឿន | ប្រុស | អនុភូមិ | ស្វាយ ឬស្សី | |
| ៣៣ | អ៊ូច ភន | ប្រុស | សមាជិកភូមិ | ស្វាយ ឬស្សី | |
| ៣៤ | ឈឹម អាន | ស្រី | មេភូមិ | ជ្រោយ ប្រយរ | |
| ៣៥ | ស៊ុំ ចាន់ | ប្រុស | អនុភូមិ | ជ្រោយ ប្រយរ | |
| ៣៦ | ឈឹម គា | ប្រុស | សមាជិកភូមិ | ជ្រោយ ប្រយរ | |

| | | | | | |
|---|---|---|---|---|---|
| ៣៧ | សួ ដុំ | ប្រុស | មេភូមិ | ធន់មន់ខាងជើង | |
| ៣៨ | ឡឹក អ៊ុច | ប្រុស | អនុភូមិ | ធន់មន់ខាងជើង | |
| ៣៩ | សាយ សុភាព | ស្រី | សមាជិកភូមិ | ធន់មន់ខាងជើង | |
| ៤០ | កែវ អយ | ប្រុស | មេភូមិ | ធន់មន់ខាងត្បូង | |
| ៤១ | សួ យ៉ាន់ | ប្រុស | អនុភូមិ | ធន់មន់ខាងត្បូង | |
| ៤២ | សាយ ស្រីមុត | ស្រី | សមាជិកភូមិ | ធន់មន់ខាងត្បូង | |

## ១.៣ នីតិវិធីក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព

[5]នៅក្នុងនីតិវិធីដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាព សមត្ថកិច្ចបានលើកយកគោលនយោបាយក្នុងការគ្រប់គ្រងភូមិ ឃុំ ដូចជា៖

-ធ្វើឱ្យប្រជាពលរដ្ឋយល់ដឹងពីច្បាប់

-តាមដានការអនុវត្តច្បាប់ជាប្រចាំ

-មានប៉ូលីសដើរល្បាត និងមានការប្តូរវេនគ្នា

-បង្កើនកម្លាំងប្រជាការពារក្នុងភូមិ

-ផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់។

## ១.៤ កម្លាំងប្រជាការពារសង្កាត់បារាយណ៍

ប្រជាការពារគឺជាកម្លាំងស្នូល និងដើរតួនាទីសំខាន់ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដើម្បីចូលរួមក្នុងកិច្ចការពារ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន និងបានសហការយ៉ាងស្អិតរមួតជាមួយកងកម្លាំងមានសមត្ថកិច្ច។

[5] ដកស្រង់ចេញពីសៀវភៅគោលនយោបាយភូមិ ឃុំសុវត្ថិភាពសង្កាត់បារាយណ៍ ក្រុងដូនកែវ ឆ្នាំ២០១០

ក្នុងនោះដែរសង្កាត់បារាយណ៍មានប៉ុស្តិ៍នគរបាល និងប្រជាការពារ ជាសេនាធិការឱ្យក្រុមប្រឹក្សាសង្កាត់ការពារសន្តិសុខសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន ពិសេសសុវត្ថិភាពចំពោះប្រជាពលរដ្ឋ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយល្បែងស៊ីសងក៏នៅតែកើតមាន ការប្រើប្រាស់គ្រឿងញៀន ការបង្ករបួសស្នាមទំនាស់ដីធ្លី គ្រោះថ្នាក់ចរាចរណ៍ និងអំពើចោរកម្ម។

# ជំពូកទី២

# ដំណើរការគ្រប់គ្រង និងការប្រព្រឹត្តទៅរបស់សង្កាត់បារាយណ៍ ក្រុងដូនកែវ

## ២.លក្ខណៈសម្បត្តិ ភូមិ ឃុំ សុវត្ថិភាព

ភូមិ ឃុំមានសុវត្ថិភាពគឺជាភូមិ ឃុំដែលមានលក្ខណៈសម្បត្តិ ៥ យ៉ាងដូចខាងក្រោម[6]៖

1. គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
2. គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់
3. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
4. គ្មានក្មេងទំនើង
5. គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

## ២.១ វិធានការមូលដ្ឋាន

លក្ខណៈសម្បត្តិ ៧ យ៉ាងនៃគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់សុវត្ថិភាព" ត្រូវបានចាត់តាំងអនុវត្តតាមវិធានការជាមូលដ្ឋានដូចខាងក្រោម៖

### ២.១.១ វិធានការ

1. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្តៈ ចាត់វិធានការឱ្យបានម៉ត់ចត់ និងទាន់ពេលវេលាក្នុងការលើកកម្ពស់ការផ្តល់សេវារដ្ឋបាល សេវាសាធារណៈ និងការអនុវត្តមូលដ្ឋាននានាលើគ្រប់វិស័យ នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ទាំងផ្នែកបរិមាណ គុណភាព ប្រសិទ្ធិភាព តម្លាភាព ពោលគឺជម្រុញឱ្យមានការផ្តល់សេវា និងកិច្ចអន្តរាគមន៍នានាកាន់តែកៀកកិតនឹងប្រជាពលរដ្ឋ សំដៅបង្កើនការទុកចិត្តពីប្រជាពលរដ្ឋកាន់តែច្រើនឡើង។
2. គ្មានបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ៖
   - ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ និងយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំអំពីច្បាប់ពាក់ព័ន្ធ និងផលប៉ះពាល់នានាដែលបណ្តាលមកពីបទល្មើសគ្រប់ប្រភេទ ជាពិសេសអំពើ លួច ឆក់ ប្លន់ ចាប់ជំរិតយកប្រាក់ ការប្រើប្រាស់អាវុធខុស

[6] ដកស្រង់ចេញពីគោលនយោបាយភូមិ ឃុំសុវត្ថិភាព អនុម័តឆ្នាំ ២០១០

ច្បាប់ និងល្បែងស៊ីសងខុសច្បាប់ ព្រមទាំងបទល្មើសធនធានធម្មជាតិ និងបរិស្ថាន ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់។

- ត្រូវចាត់វិធានការក្នុងការបង្ការ ទប់ស្កាត់ឱ្យបានជាអតិបរិមានូវការចរាចរ ការចែកចាយ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ព្រមទាំងខិតខំលុបបំបាត់ការដាំដុះ ការរក្សាទុក ការលួចកែច្នៃសារធាតុញៀនគ្រប់ប្រភេទតាមគ្រប់រូបភាពនៅតាមភូមិ ឃុំ សង្កាត់។
- ត្រូវជំរុញបំផុសចលនាអប់រំមហាជនដើម្បីចូលរួមបង្ការ ទប់ស្កាត់គ្រឿងញៀនគ្រប់ប្រភេទជាពិសេសអនុវត្តឱ្យបានទូលំទូលាយនូវខ្លឹមសារ ទិសស្លោក"បីកុំ-មួយរាយការណ៍"
  - ❖ បីកុំ
    - ○ កុំពាក់ព័ន្ធ ៖ កុំជួញដូរ កុំចែកចាយ កុំធ្វើខ្នងបង្អែក កុំឃុបឃិតនិងកុំប្រើប្រាស់គ្រឿងញៀន។
    - ○ កុំអន្តរាគមន៍៖ កុំរារាំងការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ទោះបីជាក្រុមគ្រួសារ សាច់ញាតិ និងមិត្តភក្តិក៏ដោយ។
    - ○ កុំលើកលែង៖ កុំបន្ធូរបន្ថយការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន។ សមត្ថកិច្ចពាល់ពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ និងស្មោះត្រង់វិជ្ជាជីវៈរបស់ខ្លួន ហើយជនគ្រប់រូបត្រូវគោរព និងអនុវត្តច្បាប់។
  - ❖ មួយរាយការណ៍៖ត្រូវរាយការណ៍ព័ត៌មានដល់សមត្ថកិច្ចអំពីមុខសញ្ញាជួញដូរ ចែកចាយ ប្រើប្រាស់ ទីតាំងកែច្នៃ ផលិត និងទីតាំងស្តុកគ្រឿងញៀន។
- ត្រូវសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ អនុវត្តតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន យុត្តិសាស្ត្រទាំង ០៥ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន បទបញ្ជា សារាចរណែនាំ និងផែនការយុត្តិសាស្ត្រក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាលតាមគ្រប់ដំណាក់កាល។
- ត្រូវជំរុញឱ្យមានការបំផុសចលនាចូលរួមសហការ គាំទ្រវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋទូទាំងប្រទេស ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

3. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍៖
   - ជំរុញការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋាននានា ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមា នូវហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ រួមទាំងអ្នកស្លាប់ និងរបួស ដោយត្រូវចាត់តាំងអនុវត្តឱ្យម៉ឺងម៉ាត់ តាមផែនការយុទ្ធនាការរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងផែនការសកម្មភាពរបស់អនុគណៈកម្មាធិការទី២ នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។
   - ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ នៅទីប្រជុំជន នៅតាមទីផ្សារ នៅលើដងផ្លូវ និងតាមចញ្ចើមផ្លូវ ដើម្បីសម្រួលដល់ការធ្វើដំណើរទៅមករបស់អ្នកប្រើប្រាស់ផ្លូវ និងជាពិសេសរួមចំណែកដល់ការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ដែលបណ្តាលមកពីគ្មានសណ្តាប់ធ្នាប់សាធារណៈ
4. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និង គ្មានក្មេងទំនើង
   - ចាត់វិធានការឱ្យបានជាអតិបរមាដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើអនាចារ អំពើរំលោភសេពសន្ថវៈ ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ អំពើហិង្សាក្នុងគ្រួសារដើម្បីការពារសន្តិសុខសុវត្ថិភាព ជូនប្រជាពលរដ្ឋឱ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មលើផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ដោយអនុវត្តឱ្យបានម៉ត់ចត់តាមច្បាប់ និងផែនការយុទ្ធសាស្ត្រជាតិរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិ និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។
   - ត្រូវចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសម្មភាពក្មេងទំនើងឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់និងជាប្រចាំ តាមស្មារតីនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាល សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ និងផែនការ សកម្មភាពរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក់ព័ន្ធដល់វិធានការក្នុងការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង។

5. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព៖
   - ពង្រឹងការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទនៅមូលដ្ឋាន នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ព្រមទាំងពង្រឹងសមត្ថភាព និងបច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ សំដៅលើកកម្ពស់ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមយន្តការផ្សះផ្សា ឬសម្របសម្រួលដោយបានកំណត់ដោយក្រសួងយុត្តិធម៌។
   - ខិតខំផ្សព្វផ្សាយប្រជាពលរដ្ឋ ជាពិសេសភាគីវិវាទ ឱ្យយល់កាន់តែច្បាស់អំពីខ្លឹមសារ និងសារៈសំខាន់នៃយន្តការ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងគោលដៅកាត់បន្ថយការកកស្ទះសំណុំរឿងនៅស្ថាប័នតុលាការ ការខាតបង់ពេលវេលា ថវិកាផ្ទាល់ខ្លួននិងការចំណាយថវិការដ្ឋ ព្រមទាំងបង្កើតភាពសុខដុមរមនាក្នុងសង្គម។
6. មានអនាម័យ មានសោភណ្ឌភាពល្អ និងបរិស្ថានល្អ៖
   - មានវិធានការក្នុងការគ្រប់គ្រង ថែរក្សា និងការពារធនធានធម្មជាតិ និងបរិស្ថាន អនាម័យក្នុងភូមិ ឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព ជាពិសេសយន្តការដោះស្រាយបញ្ហាសម្រាម សំណង់រឹង និងសំណល់រាវសំដៅធ្វើឱ្យភូមិឃុំ សង្កាត់ មានសោភណ្ឌភាព គ្មានសំរាម ធ្វើឱ្យការរស់នៅប្រកបដោយផាសុខភាព មានភាពថ្លៃថ្នូរ ស៊ីវិល័យ និងមានអនាគតរុងរឿង ផ្អែកតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ។
   - បញ្ជ្រាបការអប់រំដល់ប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍ និងវិធានការនានា ស្តីពីការថែទាំរក្សាបរិស្ថាន រួមទាំងវិធីសាស្ត្រនៃការថែរក្សាសុខភាព ការចូលរួមថែរក្សាអនាម័យ សុវត្ថិភាពចំណីអាហារ។ ឧទាហរណ៍៖ ការផលិតស្រាខុសបទដ្ឋានបច្ចេកទេស ការចែកចាយ ការលក់ដូរ និងប្រើប្រាស់ថ្នាំពេទ្យ គ្រឿងសម្អាង...ក្លែងក្លាយ ឬអត់គុណភាព។
7. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព មានផែនការម្ចាស់ការទុកជាមុនក្នុងការសង្គ្រោះបឋមជួយដល់អាយុជីវិត មនុស្ស សត្វ សម្បត្តិ ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានា។ ត្រូវអប់រំអំពីវិធីការពារ ទប់ស្កាត់ជំងឺឆ្លងរាតត្បាតដែលមានហានិភ័យខ្ពស់ វិធីបង្ការគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ តាមវិធានការនានាដែលកំណត់ដោយក្រសួងជំនាញ។

## ២.១.២ ផែនការសកម្មភាព

1. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តឱ្យបាននូវរបបប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យ សភាពការណ៍ ដាក់ចេញផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ

**ភូមិ ឃុំ មានសុវត្ថិភាព** ក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន (ឯកសារយោង សេចក្តីណែនាំលេខ០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩របស់ក្រសួងមហាផ្ទៃ)។

គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវមានសេនាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរ អង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

2. នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីយ៉ាងសំខាន់ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹងកងកម្លាំងនេះ ដើម្បីក្លាយទៅជាកម្លាំងស្នូលពិតប្រាកដ នៃចលនាការពារ **ភូមិ ឃុំ មានសុវត្ថិភាព** និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយៈ
    - ត្រូវរៀបចំឱ្យមានក្របខណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ
    - ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការ និងសិទ្ធិអំណាចព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល(ឯកសារយោង មេរៀនដកស្រង់ពីក្រុមការងារការអនុវត្តសាកល្បងពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍)
    - ត្រូវរៀបចំទីកន្លែងធ្វើការ មធ្យោបាយ ឧបករណ៍សម្ភារៈសម្រាប់បម្រើការងារ និងរៀបចំឱ្យមានប្រអប់សំបុត្រ
    - ត្រូវមានកម្លាំងប្តូរវេនជាប្រចាំការអចិន្ត្រៃយ៍នៅស្នាក់ការនគរបាលប៉ុស្តិ៍ដើម្បីទំនាក់ទំនងជួប និងទទួលពីគ្រប់ប្រភព។ ក្នុងករណីមានសភាពការណ៍បទល្មើសឧប្បទ្ទវហេតុផ្សេងៗកើតឡើង ចាំបាច់ត្រូវកោះហៅប្រមូលផ្តុំកម្លាំងដើម្បីប្រតិបត្តិការដោះស្រាយ។
    - ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយកងកម្លាំងមានសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីបង្កើតឱ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាក្នុងឃុំ សង្កាត់ ភូមិ
    - ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការនយោបាយ ជំនឿសាសនា ភេទ ឬ ស្ថានភាពសង្គមនៃប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់ៗរូបស្រលាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រ សហការ ចូលរួមឱ្យបានទូលំទូលាយប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងចលនា **ភូមិ ឃុំមានសុវត្ថិភាព។**

3. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវៈ
    - ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទីនៃថ្នាក់នគរបាលនីមួយៗដើម្បី ដឹកនាំត្រួតពិនិត្យ វាយតម្លៃប៉ុស្តិ៍នគរបាលឃុំ សង្កាត់ជាប្រចាំ។ ជាមួយគ្នានេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជាឱ្យអង្គភាពនគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់នៅពេលមានបទល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់។
    - មានកម្មវិធីការងារឱ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋាន ដោយត្រូវយក**ភូមិ**ជាគោលដៅ ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន ក្នុងន័យទាក់ទាញឱ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតឱ្យបានកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើស រក្សា**សុវត្ថិភាពភូមិ ឃុំ**។
4. ក្រោមការសម្របសម្រួលរបស់រដ្ឋបាលឃុំ សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅតាមភូមិនីមួយៗ ឬកម្រងភូមិត្រូវរៀបចំឱ្យមានវេទិការសាធារណៈ **ស្តីពីសុវត្ថិភាពភូមិ ឃុំ**។ វេទិកានេះធ្វើឡើងយ៉ាងតិច១ដង ក្នុង១ត្រីមាស(ឯកសារយោងផែនការណែនាំបន្ថែមស្តីពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ **ចលនាប្រជាការពារ** លេខ ០៣៨ផក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ)។ ក្នុងវេទិកានេះត្រូវធ្វើការដោះស្រាយសំណើ សំណូមពររបស់ប្រជាពលរដ្ឋដែលលើកឡើង។ ក្នុងការដោះស្រាយមិនបានត្រូវរាយការណ៍ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ឱ្យបានសមស្របជូនប្រជាពលរដ្ឋវិញ។
5. ក្រសួងមហាផ្ទៃសូមអំពាវនាវៈ
    - ដល់គ្រប់ក្រសួងស្ថាប័នគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទីភារកិច្ចរបស់ខ្លួនចេញនូវការណែនាំដល់មន្ត្រីអង្គភាពក្រោមឱវាទរបស់ខ្លួន ដើម្បីសហការលើកទឹកចិត្តឧបត្ថម្ភគាំទ្រចូលរួមជាមួយក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងគោលនយោបាយ**ភូមិ ឃុំមានសុវត្ថិភាព**។
    - ដល់គណៈបក្សនយោបាយ អង្គភាពក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជនផ្អែកតាមតួនាទី ភារកិច្ច និងលទ្ធភាពរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភ គាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាព ក្នុងការចូលរួមអនុវត្តគោលនយោបាយ**ភូមិ ឃុំមានសុវត្ថិភាព**។

៦.ត្រូវចាត់តាំងឱ្យមានចលនាប្រណាំង បង្កើតស្នាដៃអបអរសម្រាប់ខួបអនុស្សាវរីយ៍ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជាប្រចាំឆ្នាំនីមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃដ៏ធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ **ភូមិ ឃុំ មានសុវត្ថិភាព** (ឯកសារយោង សារាចរណែនាំលេខ០០១ សរ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៨ របស់ក្រសួងមហាផ្ទៃស្តីពី ការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា១៦ ឧសភា ១៩៤៥។)

## ២.២ ការចាត់តាំងអនុវត្តន៍

១.ក្រសួងមហាផ្ទៃធ្វើសេនាធិការជូនរាជរដ្ឋាភិបាលដោយត្រូវ៖

- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ព្រមទាំងដឹកនាំតាមដាន ត្រួតពិនិត្យ វំលឹកដាស់តឿន គណៈបញ្ជាការរដ្ឋបាលឯកភាពគ្រប់ថ្នាក់ ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ **ភូមិ- ឃុំ -សង្កាត់មានសុវត្ថិភាព**
- បង្កើតលេខាធិការដ្ឋានដើម្បីរៀបចំផែនការសកម្មភាព និងតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿនក្នុងការអនុវត្តលក្ខណៈសម្បត្តិនៃគោលនយោបាយ **ភូមិ- ឃុំ -សង្កាត់មានសុវត្ថិភាព** ព្រមទាំងបូកសរុបវាយតម្លៃរាយការណ៍តាមដំណាក់កាលនីមួយៗ ជូនរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការចាត់តាំងអនុវត្តគោលនយោបាយនេះ។

២. ក្រសួង ស្ថាប័ននានាចំណុះរដ្ឋាភិបាល ត្រូវរៀបចំក្រុមការងារដើម្បីជួយក្នុងការរៀបចំផែនការសកម្មភាព និងជួយតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿនក្នុងការអនុវត្តលក្ខណៈសម្បត្តិ នៃគោលនយោបាយ **ភូមិ- ឃុំ -សង្កាត់មានសុវត្ថិភាព** ដែលមានពាក់ព័ន្ធទៅនឹងវិស័យជំនាញរបស់ក្រសួង ស្ថាប័ននីមួយៗ និងត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តជូនមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃតាមការកំណត់។

# ជំពូកទី៣

# ផែនការសង្កាត់បារាយណ៍ និងកម្មវិធីវិនិយោគ

## ៣.ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច

### ៣.១.១ ស្ថានភាពភូមិសាស្ត្រ

សង្កាត់បារាយណ៍ គឺជាសង្កាត់មួយក្នុងចំណោម សង្កាត់សរុប០៣ នៃក្រុងដូនកែវ ខេត្តតាកែវ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងឃុំលំចង់ស្រុកសំរោង ខាងត្បូងជាប់នឹងសង្កាត់រកាក្រៅ ក្រុងដូនកែវ ខាងកើតជាប់នឹងឃុំព្រៃផ្គាំ ស្រុកអង្គរបុរី និងខាងលិចជាប់និងសង្កាត់រកាក្នុង ក្រុងដូនកែវ។ សង្កាត់បារាយណ៍ មានភូមិចំនួន ១៤ភូមិ ប្រជាពលរដ្ឋសរុប ២ ៨៣៨ គ្រួសារ ស្មើនឹង ១៤ ៥៩៩ នាក់ ក្នុងនោះស្រី៧ ៤១៨នាក់ និងអាយុ១៨ឆ្នាំ ឡើង សរុបចំនួន៩ ៥៨៥នាក់ ក្នុងនោះស្រី៤ ៩១៩ នាក់។ សង្កាត់បារាយណ៍មានបណ្តាញផ្លូវថ្នល់ ខ្វាត់ខ្វែង តភ្ជាប់ពីភូមិមួយទៅភូមិមួយ សម្រាប់ធ្វើចរាចរនិងការដឹកជញ្ជូន មានប្រឡាយសម្រាប់នាំទឹកស្រោចស្រពដំណាំផ្សេងៗ និងមានសាលារៀន មានមណ្ឌលសុខភាព វត្តអារាម សម្រាប់បម្រើសេវាសង្គមជូនប្រជាពលរដ្ឋ។

សង្កាត់បារាយណ៍មានផ្ទៃដីសរុបចំនួន ៤១០០ហិចតា ក្នុងនោះមាន[7]៖

- ដីស្រែវស្សា ចំនួន ១ ០០១ហិចតា
- ដីស្រែប្រាំង ចំនួន ២ ៦០០ហិចតា
- ដីចំការ ចំនួន ៣០ហិចតា
- ដីលំនៅដ្ឋានចំនួន ៣៧០ហិចតា
- ដីព្រៃក បឹង ចំនួន ៩៩ហិចតា

សង្កាត់មានប្រភពធនធានជាច្រើនដូចជា ផ្ទៃដីស្រែបង្កបង្កើនផល ស្រែវស្សា ស្រូវប្រាំង ស្រូវបង្កើនរដូវ និងមានទំនប់បឹងតាកែវ និងបឹងជ្រោយសំរោង ដែលជាប្រភពអាចទាញយកទឹកប្រើប្រាស់។

សង្កាត់មានភូមិសាស្ត្រជា០៣ សំខាន់ៗគឺ៖

១.ផ្នែកខាងលិចនិងកណ្តាល ជាប្រភេទដីស្រែវស្សា សម្រាប់ស្ទូងស្រូវវស្សា និងដាំដំណាំផ្សេងៗ។

២.ផ្នែកខាងជើង ខាងត្បូង និងខាងកើត ជាប្រភេទដីស្រែប្រាំងសម្រាប់ធ្វើស្រែប្រាំង។

[7] ដកស្រង់ចេញពីចំណុចទី១ នៃគោលនយោបាយប្រាំឆ្នាំរំកិលរបស់សង្កាត់បារាយណ៍ពីឆ្នាំ២០២៣ដល់២០២៧

៣.ផ្នែកខាងលិចជាប់មាត់បឹងតាកែវ ប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្ម និងការចិញ្ចឹមសត្វជាចម្បង។

សង្កាត់មានភូមិចំនួន ១៤ ដូចជា៖ ធន់មន់ជើង ធន់មន់ត្បូង ឫស្សី ជ្រោយប្រយរ ស្វាយជ្រំ ដូនពែង ស្វាយឫស្សី ខាន់ខាវ ត្រពាំងឫស្សី ក្រចាប់ ត្រពាំងលាក់ ចុងថ្នល់ ក្រាំងតាពូង ជ្រោយសំរោង។

### ៣.១.២ ផែនការណ៍ឃុំ ឬ ការវិនិយោគថវិកាឃុំ

នៅក្នុងឆ្នាំ២០២៣ សង្កាត់បារាយណ៍មានចំណូលតុល្យភាពចំណាយសរុបចំនួន ៨៨៨,១៤៥,៩៩៥ ៛ 00 [8]

| បរិយាយប្រភពចំណូល | ចំនួនចំណូល |
|---|---|
| • ចំណូលផ្ទាល់ជាកាតាព្វកិច្ចរបស់ឃុំ | ១១,៧០៩,៩00៛00 |
| • ចំណូលការផ្ទេរមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៣ | ៥៩៦,000,000៛00 |
| • ចំណូលពីមូលនិធិបម្រុង | ៥៧,០៣៦,០៩៥៛00 |
| • ចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ | ២២៣,000,000៛00 |
| • ចំណូលពីការចូលរួមចំណែកពីប្រជាពលរដ្ឋ | ៤00,000៛00 |
| ចំណូលសរុប | ៨៨៨,១៤៥,៩៩៥៛00 |

### ១. ផ្នែកចំណូល ៖

❖ **សរុបចំណូលចំនួន ៨៨,១៤៥,៩៩៥ រៀល ក្នុងនោះមាន៖**

➢ **ជំពូក** 73 (ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា) ៖ ១១,៧០៩,៩00 រៀល

– គណនី7302ផលពីការគ្រប់គ្រងរដ្ឋបាល ឆ្នាំ២០២៣ ៖ ៣,៦00,000 រៀល

ឆ្នាំចាស់ ៖ ៨,១០៩,៩00 រៀល

➢ **ជំពូក** 75 (ការឧបត្ថម្ភ អំណោយ) ៖៨៧៦,៤៣៦,០៩៥ រៀល

– គណនី7501(ឧបត្ថម្ភធនពីថ្នាក់ជាតិ) ៖៣៨៨,000,000 រៀល

– គណនី7503(ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍន៍ មូលដ្ឋាន) ៖២០៨,000,000 រៀល

[8] ដកស្រង់ចេញពីផែនការថវិការបស់សង្កាត់បារាយណ៍ក្រុងដូនកែវឆ្នាំ២០២៣

- គណនី7510 (មូលនិធិបំរុង) ៖ ៥៧,០៣៦,០៩៥ រៀល
- គណនី7511 (ឧបត្ថម្ភធនពីថ្នាក់ជាតិសំរាប់ចំណាយវិនិយោគ) ៖១៦៦,០០០,០០០ រៀល
- គណនី7512(ឧបត្ថម្ភធនរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសំរាប់ ចំណាយវិនិយោគ)៖៥៧,០០០,០០០ រៀល
- គណនី7513(ចំណូលពីការរួមចំណែកក្នុងការអនុវត្តគម្រោង) ៖ ៤០០,០០០ រៀល

**២. ផ្នែកចំណាយ ៖**

❖ **សរុបចំណាយចំនួន ៨៩៨,១៤៥,៩៩៥ រៀល ក្នុងនោះមាន៖**

- ជំពូក 60 (ការទិញ) ៖ ៤៤,០៨១,១០០ រៀល
- ជំពូក 61 (សេវាកម្ម) ៖៥០៣,០៦៥,២៩៥ រៀល
- ជំពូក 64 (បន្ទុកបុគ្គលិក) ៖៣២៤,០៦៩,៩០០ រៀល
- ជំពូក 62 (អត្ថប្រយោជន៍សង្គម) ៖ ៩២៩,៧០០ រៀល
- ជំពូក 69 (ចំណាយមិនបានគ្រោះទុក) ៖ ១៦,០០០,០០០ រៀល
- ជំពូក 21 (អចលកម្មរូបី) ៖ ០០ រៀល

តួលេខខាងលើនេះ គឺជាការសង្ខេប រីឯតួលេខលំអិតមានរាយបញ្ជាក់ជូនក្នុងអនុសារណៈស្តីពីការរៀបចំ ផែនការថវិកាឆ្នាំ២០២៣ ដូចមានជូនភ្ជាប់នៅឯកសារឧបសម្ព័ន្ធ។

## ៣.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

### ៣.២.១ ផ្នែកសេដ្ឋកិច្ច

ក្នុងអាណិត្តទី៤របស់ក្រុមប្រឹក្សាឃុំសង្កាត់ បានប្រើប្រាស់មូលនិធិសង្កាត់ សាងសង់ផ្លូវបេតុងអាមេបាន៣ខ្សែ ប្រវែង ២៣៦៩ម៉ែត្រ និងផ្លូវគ្រួសធម្មជាតិ១ខ្សែប្រវែង ២៥៦០ម៉ែត្រ។ ជួសជុលផ្លូវចាក់កៅស៊ូប្រភេទ DBST បានប្រវែង ៧៥០០ម៉ែត្រ ពីភូមិចុងថ្នល់ដល់ ភូមិវត្តធន់មន់សាងសង់ដោយក្រសួងអភិវឌ្ឍន៍ជនបទ និងសាងសង់ផ្លូវបេតុង១ខ្សែទៀតប្រវែង៨៩០ម៉ែត្រ ពីភូមិត្រពាំងលាក់ ដល់ភូមិត្រពាំងឫស្សីសាងសង់ដោយរដ្ឋបាលតាកែវ។

ទិន្នផលស្រូវវស្សាដែលប្រជាពលរដ្ឋបានធ្វើក្នុងឆ្នាំកន្លងមក ទទួលបានចំនួន២.៥តោន ក្នុងមួយហិចតាជាមធ្យម ចំណែកស្រូវប្រាំងទទួលបាន៥តោនទៅ៥.៥តោន ក្នុងមួយហិចតាជាមធ្យម។ផលស្រូវដែលនៅសេសសល់ពីហូបចុក ប្រជាពលរដ្ឋត្រូវបានលក់ឱ្យឈ្មួញ។ដើម្បីធ្វើឱ្យជីវភាពរស់នៅក្នុងគ្រួសារកាន់តែប្រសើរឡើង ក្រៅពីការងារបង្កបង្កើន

ផលស្រូវ ប្រជាកសិករមួយចំនួនបានចេញទៅប្រកបមុខរបរលក់ដូរនៅ ទីផ្សារ ធ្វើកម្មកររោងចក្រទាំងក្នុងនិងក្រៅប្រទេស ធ្វើជាងសំណង់ ជួសជុលម៉ូតូ ឡាន ឬដាំដំណាំរួមផ្សំផ្សេងៗទៀតតាមរដូវ។

ទន្ទឹមនឹងសក្តានុពលផ្នែកសេដ្ឋកិច្ចសង្កាត់ នៅមានបញ្ហាជាច្រើនទៀតដែលត្រូវ ប្រឈមមុខដោះស្រាយដូចជា ស្តារប្រឡាយទឹកបន្ថែមប្រវែងសរុប ៨៨៥៥ម៉ែត្រ និងជួសជុលផ្លូវលំចំនួន ១៧១៧៤ម៉ែត្រ ផ្តល់ពូជស្រូវទិន្នផលខ្ពស់ ជ្រើសរើសពូជតាមបែបធម្មជាតិ បង្កើនចំណេះដឹងផ្នែកកសិកម្មពិសេស មានផ្លូវល្អសម្រាប់ធ្វើដំណើរនិងមានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់បង្កបង្កើនផលស្រូវនិងដំណាំរួមផ្សំដែលជាសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

### ៣.២.២ផ្នែកសង្គមកិច្ច

សង្កាត់មានសាលាកម្រិតបឋមសិក្សាចំនួន ០៥ កន្លែង អនុវិទ្យាល័យ០១កន្លែង វត្ត០៥កន្លែង វិហារឥស្លាម ០១កន្លែង និងមណ្ឌលសុខភាព ០១កន្លែង។

ទោះបីជាមានមណ្ឌលសុខភាពសង្កាត់ សាលារៀន និងសេវាសុខភាពជាច្រើនក៏ដោយ ប្រជាពលរដ្ឋនៅតែជួបបញ្ហាដូចជា៖ បញ្ហាសុខភាព ដោយសារប្រជាពលរដ្ឋមួយចំនួនតូចមិនទាន់មានការយល់ដឹងច្បាស់ពីកត្តាថែរក្សាសុខភាព ពិសារទឹកឆៅ និងខ្វះអនាម័យ។ បញ្ហាកុមារមិនទាន់ទទួលបានការអប់រំគ្រប់គ្រាន់ ដោយសារមូលហេតុដូចជា គ្រួសារក្រីក្រ ឪពុកម្តាយចំណាកស្រុក អំពើហិង្សាក្នុងគ្រួសារ ល្បែងស៊ីសង និងគ្រឿងញៀនជាដើម។

បច្ចុប្បន្ននេះសង្កាត់បានរៀបចំស្ថានភាពសង្គមកិច្ចឡើងវិញឱ្យបានកាន់តែប្រសើរជាងនេះបន្ថែមទៀត ដោយបានប្រមូលផ្តុំប្រជាពលរដ្ឋហើយផ្សព្វផ្សាយអំពីការថែទាំសុខភាព ការរស់នៅប្រកបដោយអនាម័យ ផាសុខភាព និងសុខសុវត្ថិភាព ស្របតាមគោលនយោបាយ ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព។

#### ៣.២.២.១ វិស័យអប់រំ

នៅក្នុងសង្កាត់បារាយណ៍មានសាលាបឋមសិក្សាចំនួន ០៥ កន្លែង និងអនុវិទ្យាល័យចំនួន០១ កន្លែង ដូចជា៖ បឋមសិក្សាបារាយណ៍ បឋមសិក្សាត្រសក់ផ្អែម បឋមសិក្សាជ្រោយសំរោង បឋមសិក្សាធន់មន់ បឋមសិក្សាក្រចាប់ និង អនុវិទ្យាល័យបារាយណ៍។

បច្ចុប្បន្ននេះកុមារ ៩៨% នៅក្នុងសង្កាត់សុទ្ធតែបានចូលរៀនគ្រប់គ្នា ចំណែកនៅសល់មួយចំនួនតូចដែលមិនទាន់បានចូលរៀន ភាគច្រើនបណ្តាលមកពីមូលហេតុដូចជា កំព្រាឪពុកម្តាយ ឬខ្វះខាតធនធានខ្លាំង។ ចំពោះសកម្មភាពក្នុងការបង្រៀននិងសកម្មភាពផ្សេងៗដែលទាក់ទងនឹងការសិក្សារៀនសូត្រទាំងនៅក្នុង និងក្រៅសាលារៀនវិញ គឺត្រូវបានអនុវត្តយ៉ាងតឹងរឹងតាមបទបញ្ជារបស់ក្រសួងអប់រំ ដើម្បីទទួលបាននូវប្រសិទ្ធភាពខ្ពស់។

### ៣.២.២.២ វិស័យសុខាភិបាល

វិស័យសុខាភិបាល គឺជាវិស័យស្នូលមួយក្នុងចំណោមវិស័យអាទិភាពផ្សេងទៀតដែរ រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ជាពិសេសគឺសុខមាលភាពប្រជាពលរដ្ឋទាំងនៅតាមតំបន់ដាច់ស្រយាល និងទីប្រជុំជន តាមរយៈការបង្កើតថវិកាជាតិគាំទ្រដល់វិស័យអាទិភាពមួយនេះ ជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសរាជរដ្ឋាភិបាលបានផ្តើមសេវាហិរញ្ញប្បទានជំនួយសេវាពិនិត្យ ពិគ្រោះ និងព្យាបាលជំងឺជូនដល់ អ្នកជំងឺក្រីក្រ ពិសេសស្ត្រីនិងកុមារ ដើម្បីសម្រេចគោលដៅអភិវឌ្ឍសហសវត្សកាត់បន្ថយអត្រាមរណៈភាពមាតានិងទារកមុន និងក្រោយពេលសម្រាល ជំរុញស្ត្រីមានផ្ទៃពោះឱ្យទៅពិនិត្យផ្ទៃពោះជាប្រចាំ និងទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺ តេតាណូស និងទទួលបានសេវាសម្រាលទារកនៅមណ្ឌលសុខភាព។ ទន្ទឹមនឹងនេះដែរក៏មានការគាំទ្រជំនួយឧបត្ថម្ភជាសម្ភារៈ ថវិកាថ្លៃធ្វើដំណើរទៅមណ្ឌលសុខភាព ពីគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារក្នុងឃុំ(គ.ក.ន.ក) តាមរយៈមូលនិធិរបស់ឃុំផងដែរ។

### ៣.២.២.៣ ការងារយេនឌ័រ

បច្ចុប្បន្ននេះដោយរាជរដ្ឋាភិបាលបានផ្តល់លទ្ធភាពក្នុងការលើកកម្ពស់ ស្ត្រីឱ្យមានសិទ្ធិ ស្មើនឹងបុរសដែរ ស្ត្រីមានសិទ្ធិឈរឈ្មោះ ធ្វើជាអ្នកដឹកនាំនៅមូលដ្ឋាន មានសិទ្ធិបញ្ចេញមតិក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមក្នុងការសកម្មភាពអភិវឌ្ឍន៍សង្គម ការផ្សព្វផ្សាយច្បាប់ និងគោលការណ៍នានា ដើម្បីកាត់បន្ថយផលវិបាកដែលធ្លាក់មកលើស្ត្រី។

កន្លងមក ដោយមានការសហការជាមួយអង្គការក្នុង និងក្រៅរដ្ឋាភិបាល ការបញ្ជ្រាបយេនឌ័រក្នុងសង្កាត់មានការរីកចម្រើនគួរឱ្យកត់សម្គាល់ គឺនៅគ្រប់ភូមិក្នុងសង្កាត់ ស្ត្រី យុវជន និងកុមារមានសិទ្ធិ បញ្ចេញមតិយោបល់ជ្រើសរើសរកបញ្ហាតម្រូវការចាំបាច់របស់ខ្លួន។ ជាក់ស្តែង យើងបានជ្រើសរើសស្ត្រីឱ្យធ្វើជាថ្នាក់ដឹកនាំសង្កាត់ ០១នាក់ មេភូមិ ០១នាក់ អនុភូមិ ០៣នាក់ និងសមាជិកភូមិចំនួន ១១ភូមិក្នុងសង្កាត់ ដែលស្តែងឱ្យឃើញពីការកាត់បន្ថយបន្ទុកការងារ ចំពោះតួនាទីបម្រើការងាររបស់ស្ត្រីភេទក្នុងសង្កាត់។ ជាពិសេសទៅទៀត ការពន្យាកំណើត ការគាំពារមាតានិងទារក ការបំបាត់អំពើជួញដូរស្ត្រីនិងកុមារ កំពុងមានដំណើរការល្អប្រសើរ។

### ៣.២.២.៤ ការងារសាសនា

ព្រះពុទ្ធសាសនា ជាសាសនាមួយរបស់រដ្ឋ ដែលប្រជាជនភាគច្រើនប្រតិបត្តិតាម។ ជាទូទៅឃុំមានប្រជាពលរដ្ឋប្រមាណ៩៩% គោរពព្រះពុទ្ធសាសនា។ ដែលក្នុងឃុំមានវត្តអារាមចំនួន៥កន្លែង ក្រៅពីវត្តអារាមនៅតាមណ្តាលភូមិមានសាលាបុណ្យ សម្រាប់លោកតាលោកយាយដែលពិបាកធ្វើដំណើរទៅវត្តអារាមធ្វើបុណ្យទាន។ ដោយសារឥទ្ធិពលនៃជំនឿរបស់ប្រជាពលរដ្ឋតាំងក្នុងឃុំ និងក្រៅឃុំនេះហើយទើបវត្តអារាមធ្វើបុណ្យទាន។ ដោយសារឥទ្ធិពលនៃជំនឿ

របស់ប្រជាពលរដ្ឋទាំងក្នុងឃុំ និងក្រៅឃុំនេះហើយ ទើបវត្តអារាមក្នុងវិស័យព្រះពុទ្ធសាសនាគឺមានការចូលរួមច្រើនពីប្រជាពលរដ្ឋ និងការចូលរួមចំណែកក្នុងការកសាងមូលដ្ឋានភូមិ ឃុំផងដែរ ជាក់ស្តែងព្រះសង្ឃបានកៀរគរពុទ្ធបរិស័ទ ធ្វើសកម្មភាពសប្បុរសធម៌ផ្សេងៗរបស់ប្រជាជនក្រីក្រជាដើម។

### ៣.២.២.៥ ការចាកចេញទៅក្រៅប្រទេស និងការផ្លាស់ប្តូរលំនៅ

ដោយផ្អែកលើស្ថានភាពភូមិសាស្ត្ររបស់ឃុំ អំណោយផលដល់វិស័យកសិកម្ម ដោយឡែកចំពោះវិស័យរោងចក្រសហគ្រាស និងអាជីវកម្មផ្សេងៗមួយចំនួនមានក្នុងឃុំ និងបណ្តោយឃុំជិតខាង ជាហេតុធ្វើឱ្យប្រជាពលរដ្ឋក្នុងឃុំ និងក្រៅឃុំប្រកបមុខរបរតាំងទីលំនៅបណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍ ដោយសារពួកគេងាយស្រួលក្នុងការដោះដូរទំនិញខ្លះប្រកបមុខរបរជាកម្មកររោងចក្រ និងមុខរបរផ្សេងៗទៀតដើម្បីរកប្រាក់ចំណូលដោះដូរជីវភាពគ្រួសារ។

### ៣.២.២.៦ ពិការភាព និងភាពងាយរងគ្រោះ

**ក.ពិការភាព**

រាជរដ្ឋាភិបាលកម្ពុជា ដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៨ ដល់ ២០២៣ ដែលជាមូលដ្ឋានគ្រឹះ និងឆ្អឹងខ្នងដ៏សំខាន់មួយទៀតមិនអាចខ្វះបាន ក្នុងការបន្តជំរុញការអនុវត្តច្បាប់ស្តីពី កិច្ចការពារ និងលើកកម្ពស់ជីវភាព និងសិទ្ធិជនពិការ ឱ្យកាន់តែមានប្រសិទ្ធភាព និងលើកកម្ពស់ជីវភាព និងសិទ្ធិជនពិការនៅកម្ពុជា។ តាមរយៈផែនការយុទ្ធសាសាស្ត្រជាតិនេះ បានកំណត់នូវចក្ខុវិស័យ ដើម្បីឱ្យជនពិការ និងក្រុមគ្រួសារទទួលបានគុណភាពជីវិតកាន់តែប្រសើរ និងចូលរួមយ៉ាងសកម្មពេញលេញស្មើគ្នាក្នុងសង្គម ដែលមានការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរ ការទទួលសេវាយុត្តិធម៌ ការរស់នៅដោយឯករាជ្យ ការចេញផុតពីការធ្វើទារុណកម្ម ការរំលោភបំពាន ការកេងប្រវ័ញ្ច អំពើហិង្សា និងការទទួលបាននូវជំនួយគ្រាមានអាសន្ន ព្រមទាំងជំរុញឱ្យការដាក់បញ្ចូលបញ្ហាពិការភាពក្នុងការងារលើគ្រប់វិស័យទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជងដែរ។

**ខ.ភាពងាយរងគ្រោះ**

រាជរដ្ឋាភិបាល បានរៀបចំប្រព័ន្ធគាំពារសង្គមប្រកបដោយប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដើម្បីបម្រើដល់គោលនយោបាយកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ រួមចំណែកដល់ការ និងគាំពារធនធានមនុស្សឱ្យកាន់តែរឹងមាំ និងទូលំទូលាយ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការដាក់ឱ្យដំណើរការបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ) និងមូលនិធិជនពិការ (ម.ជ.ព) ព្រមទាំងបានអនុម័តនូវយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ដាក់ឱ្យដំណើរការកម្មវិធីជាតិគាំពារសង្គម ដែលមានកំណត់ក្នុងក្របខណ្ឌ

គោលនយោបាយគាំពារសង្គម ២០១៦ ដល់ ២០២៥។ តាមរយៈគោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងទាំងនេះ ធ្វើឱ្យភាពងាយរងគ្រោះរបស់ស្ត្រីនិងកុមារ ជនចាស់ជរា អតីតយុទ្ធជន ជនពិការ ជនក្រីក្រ និងជនងាយរងគ្រោះផ្សេងៗទៀតមូលដ្ឋានមានភាពប្រសើរឡើងរួមចំណែកកាត់បន្ថយភាពក្រីក្រមួយផ្នែកធំ។

### ៣.២.៣ ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

លក្ខណៈភូមិសាស្ត្រសង្កាត់បាឡាយណ៍សំបូរទៅដោយ វាលទំនាបបឹង ប្រព័ន្ធធារាសាស្ត្រសំបូរបែបដែលបន្សល់ទុកពីសម័យប៉ុលពត នៅរដូវទឹកឡើងក្លាយជាទន្លេធំល្វឹងល្វើយ មានត្រីសំបូរគួរសម មានខ្យល់ត្រជាក់បោកបក់ពីទឹកទន្លេ រីឯការចាប់ត្រីខុសច្បាប់ត្រូវបានហាមឃាត់។ មកដល់ពេលនេះសង្កាត់បានបង្កើនការយល់ដឹងអំពីច្បាប់ភូមិបាលច្បាប់សាងសង់ ច្បាប់ព្រៃឈើ ច្បាប់ជលផល ច្បាប់បរិស្ថាន។ កាត់បន្ថយការប្រើប្រាស់ថ្នាំពុលនិងសារធាតុពុលនានាដែលប៉ះពាល់បរិស្ថាននិងបង្កើនការចិញ្ចឹមត្រីតាមគ្រួសារ។ ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ បទល្មើសនេសាទ បទល្មើសធ្វើអាជីវកម្មទាញយកផលពីធនធានធម្មជាតិ។ សិក្សាផលប៉ះពាល់ មុននឹងបង្កើត ឬមុននឹងទាញយកផលពីធនធានធម្មជាតិមកប្រើប្រាស់។ ពង្រឹងបណ្តាញសហគមន៍ព្រៃឈើ និងដាំព្រៃឈើឡើងវិញ ព្រមទាំងកំណត់ទីតាំងធ្វើអាជីវកម្មធនធានធម្មជាតិឱ្យបានច្បាស់លាស់។ ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់កាន់តែច្បាស់ពីគ្រោះមហន្តរាយ និងផលប៉ះពាល់ពីគ្រោះមហន្តរាយ។ ជួសជុល និងសាងសង់ប្រព័ន្ធរំដោះទឹក ទំនប់ស្ទាក់ទឹក ទំនប់ការពារទឹកជំនន់ និងដាំដើមឈើឡើងវិញ ។ បង្កើត និងពង្រឹងកិច្ចអន្តរាគមន៍ឆ្លើយតបគ្រោះមហន្តរាយ ទាំងមុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ។ យ៉ាងណាមិញ សង្កាត់ក៏នៅមិនទាន់កែបញ្ហាបានទាំងស្រុងឡើយដោយសារប្រជាជនមួយចំនួនតូចនៅតែមិនគោរពតាមច្បាប់ ដែលបានផ្សព្វផ្សាយ។

ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ឃុំបានរួមសហការជាមួយការិយាល័យបរិស្ថានស្រុក និងផ្នែករដ្ឋបាលព្រៃឈើ ផ្នែករដ្ឋបាលជលផល និងអ្នកពាក់ព័ន្ធនានា បានធ្វើការអប់រំប្រជាពលរដ្ឋឱ្យយល់ដឹង អំពីការថែរក្សា ធនធានធម្មជាតិដែលមានស្រាប់ ហាមឃាត់ការប្រើប្រាស់គ្រឿងឆក់ និងស៊ែប្រមុងក្នុងការនេសាទនិងជំរុញការអភិរក្សព្រៃឈើ ព្រៃលិចទឹក និងដាំដើមឈើឡើងវិញ ដូចជា ដើមអង្កាដី ដើមអំពិលទឹកបារាំង ដើមសង្កែ និងដើមឈើហូបផ្លែជាច្រើន ដើម្បីគុណភាពប្រយោជន៍សម្រាប់ជាប្រភពថាមពល ចំណីអាហារ និងជាម្លប់នៅតាមសាលារៀន ទីវត្តអារាម ទំនប់ខ្នងប្រឡាយ និងទីសាធារណៈផ្សេងៗដើម្បីឱ្យមានធាតុអាកាសត្រជាក់ខ្យល់អាកាសបរិសុទ្ធ និងកាត់បន្ថយការកើនឡើងកំដៅនៃផែនដី។

## ៣.៣ ការតាមដាននិងវាយតម្លៃ ការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំ[9]

សាងសង់ផ្លូវបេតុងអាមេ (ខាន់ខាវ, ភូមិស្វាយឫស្សី, ត្រពាំងលាក់)តាមដាន និងវាយតម្លៃ ការអនុវត្តកម្មវិធីវិនិយោគតារាងបីឆ្នាំរំកិលសង្កាត់

**១.គម្រោងរបស់រដ្ឋបាលសង្កាត់បារាយណ៍៖**

– គ្រោង៖បរិមាណ១៥៩២.៨ម៉ែត្រ រយៈពេលអនុវត្ត១ឆ្នាំ តម្លៃគម្រោង ៣២០,000,000 អង្គភាពអនុវត្តគឺសង្កាត់។

– ជាក់ស្តែង៖ទទួលបានបរិមាណ៦៣៨ម៉ែត្ររយៈពេល១ឆ្នាំតម្លៃគម្រោង៣២៦,៧៥១,៤០១ អង្គភាពអនុវត្តគឺសង្កាត់។

– ភាគរយនៃការសម្រេច៖ ៤0.0៦%

- **ផ្លូវបេតុងអាមេ ( ស្វាយឫស្សី )**

– គ្រោង៖ បរិមាណ ២00ម៉ែត្រ រយៈពេលអនុវត្ត ៣ឆ្នាំ តម្លៃគម្រោង៨៣.២00.000។

– ជាក់ស្តែង៖ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេច៖ 0%

- **ផ្លូវបេតុងអាមេ ភូមិត្រពាំងឫស្សី ( ខាងលិចភូមិ )**

– គ្រោង៖បរិមាណ ៦00 ម៉ែត្រ រយៈពេលអនុវត្ត 0៣ឆ្នាំ តម្លៃគម្រោង ២៤៩.000.000។

– ជាក់ស្តែង៖ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេច៖ 0%

- **ផ្លូវបេតុងអាមេ ( ត្រពាំងលាក់ ) ខាងជើងភូមិ**

– គ្រោង៖បរិមាណ៦00ម៉ែត្រ រយៈពេលអនុវត្ត 0៣ ឆ្នាំ តម្លៃគម្រោង ២៤៩.000.000។

– ជាក់ស្តែង៖ មិនទាន់សម្រេចបាន

[9]ដកស្រង់ចេញពីផែនការអភិវឌ្ឍន៍រយៈពេលបីឆ្នាំរំកិល(២០២៣-២០២៥

– ភាគរយនៃការសម្រេចៈ 0%

- **ផ្លូវបេតុងអាមេ** (**ត្រពាំងឫស្សី,ឫស្សី,ក្រចាប់**)

– គ្រោងៈបរិមាណ ០៣ វគ្គ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ១.១៩១.៨៤0.000។

– ជាក់ស្តែងៈ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេចៈ 0%

- **ផ្លូវលំបេតុងៈ** (**ភូមិស្វាយជ្រុំ**)

– គ្រោងៈ បរិមាណ ៧00ម៉ែត្រ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ២៩១.២00.000។

– ជាក់ស្តែងៈ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេចៈ0%

- **ផ្លូវបេតុងអាមេ** (**ភូមិចុងថ្នល់**)

– គ្រោងៈបរិមាណ១១២0ម៉ែត្រ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ៤៦៥.៩២0.000។

– ជាក់ស្តែងៈ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេចៈ 0%

- **បច្ចេកទេសចិញ្ចឹមមាន់**

– គ្រោងៈបរិមាណ ១៤ វគ្គ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ៣.000.000។

– ជាក់ស្តែងៈ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេចៈ 0%

- **បច្ចេកទេសដាំបន្លែ**

– គ្រោងៈបរិមាណ ១៤ វគ្គ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ៣.000.000។

– ជាក់ស្តែងៈ មិនទាន់សម្រេចបាន។

- ភាគរយនៃការសម្រេច៖ 0%

- **បច្ចេកទេសបណ្ដុះផ្សិតចំបើង**

- គ្រោង៖បរិមាណ ១៤ វគ្គ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ៣.០០០.០០០។

- ជាក់ស្តែង៖ មិនទាន់សម្រេចបាន។

- ភាគរយនៃការសម្រេច៖0%

- **អាហារូបត្ថម្ភសហគមន៍**

- គ្រោង៖ បរិមាណ ០២ វគ្គ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ៣.០០០.០០០។
- ជាក់ស្តែង៖ មិនទាន់សម្រេចបាន។
- ភាគរយនៃការសម្រេច៖ 0%

- **វ៉ាក់សាំងគោ ក្របី**

- គ្រោង៖ បរិមាណ ៤០៥០ ក្បាល រយៈពេលអនុវត្ត ០១ ឆ្នាំ អង្គភាពអនុវត្តគឺកសិកម្មខេត្ត។

- ជាក់ស្តែង៖ទទួលបានបរិមាណ៣៥០០ ក្បាល រយៈពេលអនុវត្ត ០១ ឆ្នាំ។

- ភាគរយនៃការសម្រេច៖ ៨៦%

- **បច្ចេកទេសប្រើថ្នាំពុល និងការពារសុខភាព**

- គ្រោង៖បរិមាណ ០៣ វគ្គ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ៣.០០០.០០០។

- ជាក់ស្តែង៖ មិនទាន់សម្រេចបាន។

- ភាគរយនៃការសម្រេច៖ 0%

- ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

- គ្រោង៖ បរិមាណ ០៣ វគ្គ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង ១.៥០០.០០០។

- ជាក់ស្តែង៖ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេច៖ 0%

- ផ្សព្វផ្សាយការងារអត្រានុកូលដ្ឋាន

– គម្រោង៖ បរិមាណ ១២ ខែ រយៈពេលអនុវត្ត ០១ ឆ្នាំ តម្លៃគម្រោង ១.៣២០.០០០ អង្គភាពអនុវត្តគឺសង្កាត់។

– ជាក់ស្តែង៖ ទទួលបានបរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ១.៣២០.០០០ អង្គភាពអនុវត្តគឺសង្កាត់។

– ភាគរយនៃការសម្រេច៖ ១០០%

- ផ្សព្វផ្សាយពីសេវាសុខភាពនៅមណ្ឌលសុខភាពបារាយណ៍

– គ្រោង៖ បរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ១.២៧២.០០០ អង្គភាពអនុវត្តគឺសង្កាត់។

– ជាក់ស្តែង៖ ទទួលបានបរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ១.២៧២.០០០ អង្គភាពអនុវត្តគឺសង្កាត់។

– ភាគរយនៃការសម្រេច៖ ១០០%

- ផ្សព្វផ្សាយអនាម័យទឹកស្អាត

– គ្រោង៖ បរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ១.២៩៦.០០០ អង្គភាពអនុវត្តគឺសង្កាត់។

– ជាក់ស្តែង៖ ទទួលបានបរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ ឆ្នាំ តម្លៃគម្រោង ១.២៩៦.០០០ អង្គភាពអនុវត្តគឺសង្កាត់

– ភាគរយនៃការសម្រេច៖ ១០០%

- គាំទ្រការធ្វើដំណើរស្ត្រីសម្រាល

– គម្រោង៖ បរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ៣.៨៤០.០០០ អង្គភាពអនុវត្តគឺសង្កាត់។

– ជាក់ស្តែង៖ទទួលបានបរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ៣.៨៤០.០០០ អង្គភាពអនុវត្តគឺសង្កាត់។

– ភាគរយនៃការសម្រេច៖ ១00%

- ទិញសាប៊ូអនាម័យចែកសហគមន៍

– គ្រោង៖បរិមាណ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ២.៤00.000 អង្គភាពអនុវត្តគឺសង្កាត់។

– ជាក់ស្តែង៖ ទទួលបានបរិមាណ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ២.៤00.000 អង្គភាពអនុវត្តគឺសង្កាត់។

– ភាគរយនៃការសម្រេច៖ ១00%

- ផ្សព្វផ្សាយប្រជាពលរដ្ឋដាំដើមឈើ

– គ្រោង៖ បរិមាណ ០៣ វគ្គ រយៈពេលអនុវត្ត ០៣ឆ្នាំ តម្លៃគម្រោង ៣.000.000។

– ជាក់ស្តែង៖ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេច 0%

- ផ្សព្វផ្សាយប្រជាពលរដ្ឋយល់ដឹងពីបម្រែបម្រួលអាកាសធាតុ

– គ្រោង៖ បរិមាណ ០៣ វគ្គ រយៈពេលអនុវត្ត០៣ឆ្នាំ តម្លៃកម្រោង ៣.000.000។

– ជាក់ស្តែង៖ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេច៖ 0%

- ប្រជុំផ្សព្វផ្សាយទប់ស្កាត់ល្បែងស៊ីសងក្នុងសហគមន៍

– គ្រោង បរិមាណ ០៣វគ្គ រយៈពេលអនុវត្ត ០៣ ឆ្នាំ តម្លៃគម្រោង៣.000.000។

– ជាក់ស្តែង៖ មិនទាន់សម្រេចបាន។

– ភាគរយនៃការសម្រេច៖0%

- ទប់ស្កាត់បទល្មើសគ្រឿងញៀន

- គ្រោង៖ បរិមាណ ០៣វគ្គ រយៈពេលអនុវត្ត ០៣ឆ្នាំ តម្លៃគម្រោង ២.០០០.០០០។
- ជាក់ស្តែង៖ មិនទាន់សម្រេចបាន។
- ភាគរយនៃការសម្រេច៖0%
- អប់រំទប់ស្កាត់បើកបរពេលស្រវឹង
- គ្រោង៖ បរិមាណ ០១ វគ្គ រយៈពេលអនុវត្ត ០១ ឆ្នាំ តម្លៃគម្រោង ១.២០០.០០០។
- ជាក់ស្តែង៖ មិនទាន់សម្រេចបាន។
- ភាគរយនៃការសម្រេច៖0%
- ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន (ចលនាប្រជាការពារ)
- គ្រោង៖ បរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ៨.៤២១.០០០។
- ជាក់ស្តែង៖ ទទួលបានបរិមាណ ១២ខែ រយៈពេលអនុវត្ត ០១ឆ្នាំ តម្លៃគម្រោង ៨.៤២១.០០០។
- ភាគរយនៃការសម្រេច៖ ១00%

២.ការផ្តល់សេវារដ្ឋបាល របស់រដ្ឋបាលសង្កាត់៖

- អត្រានុកូលដ្ឋាន កំណើត
- គ្រោង៖ បរិមាណ ៤៦៦ សន្លឹក រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។
- ជាក់ស្តែង៖ទទួលបានបរិមាណ ៤០៨ សន្លឹក រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។
- ភាគរយនៃការសម្រេច៖ ៨៧.៥៥%
- អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍
- គ្រោង៖ បរិមាណ ១៣៨ សន្លឹ រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។
- ជាក់ស្តែង៖ទទួលបានបរិមាណ៤២សន្លឹករយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

- ភាគរយនៃការសម្រេចៈ៣០.៤៣%

- អត្រានុកូលដ្ឋានមរណភាព

- គ្រោងៈបរិមាណ ៦០ សន្លឹក រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

- ជាក់ស្តែងៈទទួលបានបរិមាណ ៦៣ សន្លឹក រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

- ភាគរយនៃការសម្រេចៈ១០៥%

- កិច្ចសន្យាខ្ចីប្រាក់

- គ្រោងៈបរិមាណ ៧៥០សន្លឹក រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

- ជាក់ស្តែងៈទទួលបានបរិមាណ៣៥៣ សន្លឹក រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

- ភាគរយនៃការសម្រេចៈ ៤៣.៨៧%

- លិខិតបញ្ជាក់ផ្សេងៗ

- គ្រោងៈបរិមាណ៧៩១ សន្លឹក រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

- ជាក់ស្តែងៈទទួលបានបរិមាណ ៦០ សន្លឹក រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

- ភាគរយនៃការសម្រេចៈ ៤៤.៦៣%

៣.ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលសង្កាត់[10]

- ដីកា

- គ្រោងៈ បរិមាណ០១ ដង រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

- ជាក់ស្តែងៈទទួលបានបរិមាណ០២ដង រយៈពេលអនុវត្ត ០១ឆ្នាំអង្គភាពអនុវត្តគឺសង្កាត់។

- ភាគរយនៃការសម្រេចៈ ២០០%

[10] ដកស្រង់ចេញពីកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥)សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ

- សេចក្តីសម្រេច

– គ្រោង៖ បរិមាណ ០៤ ដង រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

– ជាក់ស្តែង៖ទទួលបាន ០៧ ដង រយៈពេលអនុវត្ត ០១ឆ្នាំ អង្គភាពអនុវត្តគឺសង្កាត់។

– ភាគរយនៃការសម្រេច៖ ១៧៥%។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើយើងអាចសន្និដ្ឋាន និងនិយាយបានថា ដំណើរការនៃការអនុវត្តគោលនយោបាយភូមិ ឃុំសុវត្ថិភាពគឺពិតជាមានលក្ខណៈល្អប្រសើរ និងពិតជាផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ ដូចជាផ្តល់សេវាសាធារណៈកាន់តែមានគុណភាព តម្លាភាព ការជឿទុកចិត្ត គ្មានបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសង មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍ គ្មានអំពើអនាចារ ការជួញដូរមនុស្ស អំពើហិង្សា ក្មេងទំនើង ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព ប្រសិទ្ធិភាព មានអនាម័យសោភណ្ឌភាពល្អ បរិស្ថានល្អ ឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតសាហាវនានា។

ដោយសារមានការរួមផ្សំទាំងអស់នេះហើយ ទើបធ្វើឱ្យគោលនយោបាយភូមិ ឃុំសុវត្ថិភាពសង្កាត់បារាយណ៍អាចថែរក្សាបានសុវត្ថិភាពក្នុងភូមិ ឃុំ និងជំរុញឱ្យគោលនយោបាយនេះកាន់តែទទួលបាននូវភាពជោគជ័យ។

សរុបសេចក្តីមកក្រុមយើងខ្ញុំអាចសន្និដ្ឋានបានថា ការអនុវត្តគោលនយោបាយភូមិ ឃុំសុវត្ថិភាព ពិសេសទៅលើសង្កាត់បារាយណ៍ ខេត្តតាកែវគឺប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរណាស់ បើប្រៀបធៀបទៅខណៈពេលដែលមិនទាន់មានគោលនយោបាយភូមិ ឃុំសុវត្ថិភាព។

មិនត្រឹមតែប៉ុណ្ណោះប្រជាពលរដ្ឋក៏រស់នៅបានសុខសាន្ត សេដ្ឋកិច្ចក៏មានភាពល្អប្រសើរ ព្រមទាំងការអភិវឌ្ឍភូមិ ឃុំក៏មានភាពជឿនលឿនទៅមុខផងដែរ។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្វែងយល់អំពីគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព នៅសង្កាត់បារាយណ៍ ខេត្តតាកែវ កន្លងមកនាំឱ្យយើងសង្កេតឃើញថា សង្កាត់បារាយណ៍បាន អនុវត្តតាមគោលនយោបាយបានយ៉ាងល្អប្រសើរ។ ទន្ទឹមនឹងការអនុវត្តបានល្អនេះ ក៏មានចំណុចខ្វះខាតមួយចំនួនលើផែនការខ្លះរបស់សង្កាត់។ ដូច្នេះដើម្បីឱ្យទទួលបាននូវការអនុវត្តពេញលេញ និងល្អឥតខ្ចោះទៅតាមគោលនយោបាយ ដែលសម្តេចទ្រង់បានដាក់ឱ្យអនុវត្ត សង្កាត់គួរបន្ថែមសកម្មភាពមួយចំនួនដូចខាងក្រោមៈ

- បង្កើតកិច្ចប្រជុំក្នុងភូមិ ឃុំយ៉ាងហោចបីខែម្តង ដើម្បីជួបពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងការពង្រឹងបន្ថែមនូវសុវត្ថិភាពកន្លែងដែលមានការខ្វះខាត។
- ធ្វើការបិទប្រកាសនិងផ្សព្វផ្សាយប្រព័ន្ធទំនាក់ទំនងរបស់ប្រជាការពារភូមិ ឃុំតាមរយៈលេខទូរសព្ទនិងប្រព័ន្ធតេលេក្រាម
- បន្ថែមអំពូលភ្លើងនៅតាមដងផ្លូវក្នុងភូមិទាំងអស់ ដើម្បីផ្តល់ជាភាពងាយស្រួលនិងសុវត្ថិភាពក្នុងពេលធ្វើដំណើរនៅពេលយប់ និងជៀសវាងអំពើចោរកម្មផ្សេងៗ។

## ឧបសម្ព័ន្ធទី១

ក្រសួងមហាផ្ទៃ

# ផែនការណែនាំស្តីពី

# ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព"

**លក្ខណៈសម្បត្តិភូមិ ឃុំ មានសុវត្ថិភាពរួមមាន៖**

១. គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ

២. គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤. គ្មានក្មេងទំនើង

៥. គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ

**រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

ក្រសួងមហាផ្ទៃ

*លេខ៖ ០២០ ផ.ក*

# ផែនការណែនាំ
## ស្តីពី
## ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ, ឃុំមានសុវត្ថិភាព"

*សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងទៀតមានការរីកចំរើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីយើងមានសន្តិភាព ស្ថេរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឲ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ។*

*នាឱកាសមិទ្ទីញរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០* **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ជាច្រើន ដែលក្នុងនោះបានកំណត់យកគោលការណ៍កសាង***ភូមិ, ឃុំមានសុវត្ថិភាព** *ដើម្បីលើកកំពស់ និងជំរុញចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅគ្រប់ពេល និងគ្រប់ច្រកល្ហក ទូទាំងព្រះរាជាណាចក្រកម្ពុជា ។*

*ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លានេះ ក្រសួងមហាផ្ទៃបានកំណត់យក***ភូមិ, ឃុំមានសុវត្ថិភាព** *ធ្វើជាគោលនយោបាយអាទិភាពមួយសំរាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឲ្យបានគត់មត់ល្អនៅគ្រប់ភូមិ, ឃុំទូទាំងប្រទេស ។*

*ដើម្បីអនុវត្តឲ្យបានជោគជ័យគោលនយោបាយខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំចាត់តាំងអនុវត្ត ដែលមានខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖*

### I-<u>គោលបំណង និងសំណូមពរ ៖</u>

*ព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រឲ្យកាន់តែបានល្អប្រសើរថែមទៀត ។*

*៤-បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្ត **គោលនយោបាយភូមិ, ឃុំមានសុវត្ថិភាព** ។*

## II-<u>លក្ខណៈសម្បត្តិ ភូមិ, ឃុំមានសុវត្ថិភាព</u>

***ភូមិ, ឃុំមានសុវត្ថិភាព គឺភូមិ, ឃុំដែលមានលក្ខណៈសម្បត្តិ ៥យ៉ាង ដូចខាងក្រោម៖***

*១-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ*

*២-គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់*

*៣-គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ*

*៤-គ្មានក្មេងទំនើង*

*៥-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។*

## III-<u>វិធានការ និងផែនការសកម្មភាព</u>

### ក-<u>វិធានការ៖</u>

*១-ចាត់វិធានការលុបបំបាត់ឲ្យបានបទល្មើសលួច ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការជំនាញ វិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន ។*

*២-ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឲ្យបានការផលិត ការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ, ឃុំ, សង្កាត់ ដោយអនុវត្តតាមផែនការណែនាំលេខ ០៥២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងជាពិសេសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។*

*៣-ចាត់វិធានការលុបបំបាត់រាល់អំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឲ្យរួចផុតពី*

ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ) ដោយអនុវត្តតាមច្បាប់ដែលមានជាធរមានឲ្យបានម៉ឺងម៉ាត់ ។

**៤**-ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ (ឯកសារយោង៍ សារាចរលេខ ០៤ស.រ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ ០២១ស.ណ.ន ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៥០ផ.ក ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង) ។

**៥**-ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់អាវុធខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន ។

**ខ-ផែនការសកម្មភាព៖**

**១**-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវអនុវត្តអោយបាននូវរបបប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យសភាពការណ៍ ដាក់ចេញផែនការ និងវិធានការដាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ**ភូមិ, ឃុំមានសុវត្ថិភាព** ក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន (ឯកសារយោង៍ សេចក្តីណែនាំ លេខ២០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ) ។

គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវមានសេនាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរអង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ។

**២**-នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីយ៉ាងសំខាន់ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹងកងកម្លាំងនេះ ដើម្បីក្លាយទៅជាកំលាំងស្នូលពិតប្រាកដ នៃចលនាការពារ "**ភូមិ, ឃុំ មានសុវត្ថិភាព**" និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយ ៖

-ត្រូវរៀបចំឲ្យមានក្របខ័ណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ

-ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការ និងសិទ្ធិអំណាច ព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល (ឯកសារយោង៍ មេរៀនដកស្រង់ពីក្រុមការងារ ការអនុវត្តសាកល្បងការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍)

-ត្រូវរៀបចំឲ្យមានទីកន្លែងធ្វើការ មធ្យោបាយ ឧបករណ៍សំភារៈសំរាប់បំរើការងារ និងរៀបចំឲ្យមានប្រអប់សំបុត្រ និង

-ត្រូវមានកម្លាំងប្តូរវេនប្រចាំការជាអចិន្ត្រៃយ៍នៅស្នាក់ការនគរបាលប៉ុស្តិ៍រដ្ឋបាលដើម្បីទំនាក់ទំនងជួប និងទទួលព័ត៌មានពីគ្រប់ប្រភព ។ ក្នុងករណីមានសភាពការណ៍បទល្មើស ឬឧប្បទ្ទវហេតុផ្សេងៗកើតឡើង ចាំបាច់ត្រូវកោះហៅប្រមូលផ្តុំកម្លាំងដើម្បីប្រតិបត្តិការណ៍ដោះស្រាយ ។

-ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយកងកម្លាំងមានសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាក្នុងឃុំ សង្កាត់ ភូមិ និង

-ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការនយោបាយ ជំនឿសាសនា ភេទ ឬស្ថានភាពសង្គមនៃប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់ៗរូបស្រឡាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រ សហការ ចូលរួមឲ្យបានទូលំទូលាយប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងចលនា**ភូមិ, ឃុំមានសុវត្ថិភាព** ។

### ៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវ៖

-ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទីនៃនគរបាលថ្នាក់នីមួយៗ ដើម្បីដឹកនាំ ត្រួតពិនិត្យ វាយតម្លៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ, សង្កាត់ជាប្រចាំ ។ ជាមួយនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវបញ្ជាអោយអង្គភាពនគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ, សង្កាត់ នៅពេលមានបទល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់ ។

-មានកម្មវិធីការងារឲ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋាន ដោយត្រូវយក**ភូមិ**ធ្វើជាគោលដៅ ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន ក្នុងន័យទាក់ទាញឲ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតបានជាកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើស រក្សា**សុវត្ថិភាពភូមិ, ឃុំ** ។

៤-ក្រោមការសំរបសំរួលរបស់រដ្ឋបាលឃុំ, សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅតាមភូមិនិមួយៗ ឬកម្រងភូមិត្រូវរៀបចំឲ្យមានវេទិការសាធារណៈ **ស្តីពីសុវត្ថិភាពភូមិ, ឃុំ** ។ វេទិការនេះធ្វើឡើងយ៉ាងតិច ១ដង ក្នុង ១ត្រីមាស (ឯកសារយោងផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ "**ចលនាប្រជាការពារ**" លេខ ០៣៨៨ក ចុះថ្ងៃទី០៣ ខែវិច្ឆកា ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ) ។ ក្នុងវេទិការនេះត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋដែលលើកឡើង ។ ក្នុងករណីដោះស្រាយ

*មិនបាន ត្រូវរាយការណ៍ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ឲ្យបានសមស្របជូនប្រជាពលរដ្ឋវិញ ។*

***៥-ក្រសួងមហាផ្ទៃសូមអំពាវនាវ៖***

*-ដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទី ភារកិច្ចរបស់ខ្លួន ចេញនូវការណែនាំដល់មន្ត្រី អង្គភាព ក្រោមឱវាទរបស់ខ្លួន ដើម្បីសហការ លើកទឹកចិត្ត ឧបត្ថម្ភ គាំទ្រ ចូលរួមជាមួយក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងការអនុវត្តគោលនយោបាយ* ***ភូមិ, ឃុំមានសុវត្ថិភាព*** *។*

*-ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ... ផ្អែកតាមតួនាទី ភារកិច្ច និងលទ្ធភាពរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភ គាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាព ចូលរួមក្នុងការអនុវត្តគោលនយោបាយ* ***ភូមិ, ឃុំមានសុវត្ថិភាព*** *។*

***៦***-*ត្រូវចាត់តាំងឲ្យមានចលនាប្រឡងប្រណាំង បង្កើតស្នាដៃអបអរសាទរសំរាប់ខួបអនុស្សាវរីយ៍ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជាប្រចាំឆ្នាំនិមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ* ***"ភូមិ ឃុំ មានសុវត្ថិភាព"*** *(ឯកសារយោង សារាចរណែនាំលេខ ០០១ ស.រ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរសាទរមិទ្ទិញខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា១៦ ឧសភា ១៩៤៥) ។*

**IV-ការចាត់តាំងអនុវត្ត៖**

***១***-*ក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ ដើម្បី សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ដឹកនាំ និងចាត់តាំងអនុវត្តគោលនយោបាយ****ភូមិ, ឃុំ មានសុវត្ថិភាព****នេះ ។ (ភ្ជាប់ជាមួយឧបសម្ព័ន្ធ) ។*

***២***-*គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រៅពីសេនាធិការរបស់ខ្លួន ត្រូវរៀបចំអោយមានក្រុមការងារចុះតាមមូលដ្ឋានឃុំ សង្កាត់ ដោយយក****ភូមិ****ជាគោលដៅដើម្បីសហការអនុវត្តគោលនយោបាយ****ភូមិ, ឃុំ មានសុវត្ថិភាព*** *។*

***៣***-*គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបូកសរុបលទ្ធផលអនុវត្តគោលនយោបាយ* ***"ភូមិ, ឃុំ មានសុវត្ថិភាព"*** *ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើរមកលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តាមតារាងទិន្នន័យដែលភ្ជាប់ជាឧបសម្ព័ន្ធនៃផែនការណែនាំនេះ ដើម្បីមានមូលដ្ឋានវាយតម្លៃលទ្ធផល និងស្នាដៃតាមឃុំ សង្កាត់ និមួយៗ ។*

៤-គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវចាត់តាំងប្រជុំបូកសរុប ដកពិសោធន៍ និង លើកទិសដៅបន្តក្នុងរយៈពេល ០១ត្រីមាសម្តង ។ សមាសភាពចូលរួមក្នុងអង្គប្រជុំនេះ គឺអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរបស់ខ្លួន និងអាស្រ័យដោយប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលសំរេច ។

៥-ដើម្បីទទួលបានបទពិសោធន៍ឈានទៅកែលំអរផែនការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ឲ្យកាន់តែល្អប្រសើរថែមទៀត គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់អាចជ្រើសរើសមូលដ្ឋានមួយ ឬពីរ ដើម្បីអនុវត្តសាកល្បង បន្ទាប់មកទើបធ្វើការផ្សព្វផ្សាយ និងចាត់តាំងអនុវត្តជាទូទៅ ។

៦-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃលក្ខណៈសម្បត្តិរបស់**ភូមិ, ឃុំ មានសុវត្ថិភាព** ។ តាមរយៈនេះត្រូវរកឲ្យឃើញអង្គភាព និងបុគ្គលដែលមានស្នាដៃល្អ ដើម្បីផ្តល់រង្វាន់លើកទឹកចិត្ត ។

៧-អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ត្រូវធ្វើគំរោងថវិកា មធ្យោបាយ សំភារៈ បំរើដល់ការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ។

ទទួលបានផែនការណែនាំស្តីពីការអនុវត្តគោលនយោបាយ**ភូមិ, ឃុំមានសុវត្ថិភាព**នេះ ក្រសួងមហាផ្ទៃសង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួមអនុវត្ត និងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបានជោគជ័យក្នុងការកសាងសេចក្តីសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋយើង ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៙៛

## កំណត់ហេតុ

## ស្តីពីការប្រជុំពេញអង្គ ក្រុមប្រឹក្សាសង្កាត់

## ដើម្បីអនុម័តផែនការថវិកាសង្កាត់បាភយណ៍ ឆ្នាំ ២០២៣

៚៙៛

ឆ្នាំពីរពាន់ម្ភៃពីរ ខែវិច្ឆិកា ថ្ងៃទីដប់ប្រាំ វេលាម៉ោងប្រាំពីរ និងសាមសិបនាទីព្រឹកនៅសាលាសង្កាត់បាភយណ៍ ក្រុមប្រឹក្សាសង្កាត់បានបើកសម័យប្រជុំពេញអង្គជាវិសមញ្ញក្រុមប្រឹក្សាសង្កាត់ ដើម្បីពិនិត្យពិភាក្សាអនុម័តផែនការថវិកាសង្កាត់ឆ្នាំ ២០២៣ ។ អង្គប្រជុំស្ថិតក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់របស់លោក ម៉ែន ចឹម ប្រធានក្រុមប្រឹក្សាសង្កាត់បាភយណ៍។

រីឯសមាសភាពចូលរួមមានជាអាទិ៍ ៖

1. លោក ម៉ែន ចឹម ជា ប្រធានក្រុមប្រឹក្សាសង្កាត់
2. លោក ជឹង ធី ជា សមាជិកក្រុមប្រឹក្សាសង្កាត់
3. លោក រឿង ជឿន ជា សមាជិកក្រុមប្រឹក្សាសង្កាត់
4. លោកស្រី ស្វាយ ចិន្តា ជា សមាជិកក្រុមប្រឹក្សាសង្កាត់
5. លោក អេង អៀក ជា សមាជិកក្រុមប្រឹក្សាសង្កាត់
6. លោក ម៉ូវ ឡេង ជា សមាជិកក្រុមប្រឹក្សាសង្កាត់
7. លោក អ៊ុំ សួភឿន ជា សមាជិកក្រុមប្រឹក្សាសង្កាត់
8. លោក ទុំ ចំរើន ជា សមាជិកក្រុមប្រឹក្សាសង្កាត់
9. លោក ញ៉ីវ សារឿន ជា សមាជិកក្រុមប្រឹក្សាសង្កាត់

ក្រោយពីការជួបជុំ និងការពិនិត្យកូរ៉ុមគ្រប់ចំនួនអាចដំណើការប្រជុំបាន លោកប្រធានក្រុមប្រឹក្សាសង្កាត់បានលើកឡើងបញ្ជាក់ជូនអង្គប្រជុំនាថ្ងៃនេះ ដោយសង្កត់ធ្ងន់ថា ការជួបជុំនាថ្ងៃនេះក្នុងរបៀបវារៈ សំខាន់បំផុត គឺៈ ***ការពិនិត្យពិភាក្សា និងអនុម័តគម្រោងផែនការថវិកាឆ្នាំ ២០២៣*** ហើយលោកបានសុំឱ្យអង្គសមាជិកទាំងអស់ធ្វើការពិនិត្យ និងអនុម័តរបៀបវារៈជាមុនទើបអាចដំណើរការប្រជុំទៅបាន ។ បន្ទាប់មកអង្គ ប្រជុំ បានអនុម័តជាឯកច្ឆ័ន្ទលើសំលេងភាគច្រើនដាច់ខាត ៩ លើ ៩ រូបហើយអង្គប្រជុំក៏ចាប់ដំណើរការតាមកម្មវិធី ដែលបានគ្រោងទុក ។

ជាកិច្ចដំណើរការលោកប្រធានអង្គប្រជុំ បានធ្វើរបាយការណ៍ជូនអង្គប្រជុំ ពីដំណើរការរៀបចំផែនការថវិកាឆ្នាំ ២០២៣ ក្នុងនាមជាប្រធានគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់បាភយណ៍ រួមជាមួយនឹងសមាជិកទាំងអស់ ក្រោយពីបានទទួលលិខិតលេខ ៦៥៩៦ ស.ហ.វ-ហម ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២២ របស់ក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់ ទូទាំងប្រទេសសម្រាប់ឆ្នាំ២០២៣ និងរាល់បណ្តាលិខិត បទដ្ឋានពាក់ព័ន្ធនានា ត្ចបផ្សំការផ្តល់តួលេខសរុបស្តីពីស្ថានភាពនៃការអនុវត្តន៍ថវិកាសង្កាត់ឆ្នាំ ២០២២ ជាបណ្តោះអាសន្នពីគណនេយ្យករឃុំសង្កាត់នៅរតនាគារខេត្ត យើងបានដំណើរការ ពិនិត្យ ពិភាក្សា ជាមួយគណៈកម្មាធិការ កសាងផែនការ និងថវិកាសង្កាត់ រៀបចំសេចក្តីព្រាងគម្រោងផែនការថវិកាឆ្នាំ ២០២៣ ដែលត្រូវអនុវត្ត រួមមានសកម្មភាព ចំណូល និងចំណាយ តាមបណ្តាជំពូក គណនី និងអនុគណនី នៃថវិកានីមួយៗ ជាសង្ខេប ដូចខាងក្រោម ៖

១.**ផ្នែកចំណូល** ៖

- ❖ សរុបចំណូលចំនួន ៖ **៨៨៨,១៤៥,៩៩៥ រៀល** ក្នុងនោះមាន
  - **ជំពូក** 73 (ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា) ៖ ១១,៧០៩,៩០០ រៀល
  - \+ គណនី7302ផលពីការគ្រប់គ្រងរដ្ឋបាល ឆ្នាំ២០២៣ ៖ ៣,៦០០,០០០ រៀល
  - ឆ្នាំចាស់ ៖ ៨,១០៩,៩០០ រៀល
  - **ជំពូក** 75 (ការឧបត្ថម្ភ អំណោយ) ៖ ៨៧៦,៤៣៦,០៩៥ រៀល
  - \+ គណនី7501(ឧបត្ថម្ភកធនពីថ្នាក់ជាតិ) ៖ ៣៨៨,០០០,០០០ រៀល
  - \+ គណនី7503(ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន) ៖ ២០៨,០០០,០០០ រៀល
  - \+ គណនី7510(មូលនិធិបំរុង) ៖ ៥៧,០៣៦,០៩៥ រៀល
  - \+ គណនី7511(ឧបត្ថម្ភធនពីថ្នាក់ជាតិសំរាប់ចំណាយវិនិយោគ) ៖ ១៦៦,០០០,០០០ រៀល
  - \+ គណនី7512(ឧបត្ថម្ភធនរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសំរាប់ចំណាយវិនិយោគ) ៖ ៥៧,០០០,០០០ រៀល
  - \+ គណនី7513(ចំណូលពីការរួមចំណែកក្នុងការអនុវត្តគម្រោង) ៖ ៤០០,០០០ រៀល

២.**ផ្នែកចំណាយ** ៖

- ❖ សរុបចំណាយចំនួន ៖ **៨៨៨,១៤៥,៩៩៥ រៀល** ក្នុងនោះមាន
  - ជំពូក 60 (ការទិញ) ៖ ៤៤,០៨១,១០០ រៀល
  - ជំពូក 61 (សេវាកម្ម) ៖ ៥០៣,០៦៥,២៩៥ រៀល
  - ជំពូក 64 (បន្ទុកបុគ្គលិក) ៖ ៣២៤,០៦៩,៩០០ រៀល
  - ជំពូក 62 (អត្ថប្រយោជន៍សង្គម) ៖ ៩២៩,៧០០ រៀល
  - ជំពូក 69 (ចំណាយមិនបានគ្រោទុក) ៖ ១៦,០០០,០០០ រៀល
  - ជំពូក 21 (អចលកម្មវ្រី) ៖ ០០ រៀល

តួលេខខាងលើនេះ គឺជាការសង្ខេប រីឯតួលេខលំអិតមានរាយបញ្ជាក់ជូនក្នុងអនុសារណៈស្តីពីការរៀបចំផែនការថវិកាឆ្នាំ២០២៣ ព្រមទាំងតារាងឧបសម្ព័ទី១ ទី២ និងតារាងលម្អិតការ ចំណាយថវិកាសង្កាត់ ដែលជាឯកសារឧបសម្ព័ន្ធដែលបានជូនភ្ជាប់ និងសូមដាក់សេចក្តីព្រាងផែនការថវិកាសង្កាត់ឆ្នាំ២០២៣ នេះជូនលោក លោកស្រី ជាសមាជិកក្រុមប្រឹក្សាសង្កាត់ទាំងអស់ធ្វើការពិភាក្សា និងអនុម័ត ដើម្បីបញ្ជូនទៅសុំការបញ្ជាក់ទទួលស្គាល់ និងធ្វើអនុលោមភាពពីឯកឧត្តមអភិបាលខេត្តតាកែវ ជាផ្លូវការទើបអាចដំណើរការអនុវត្តថវិកាសំរាប់ឆ្នាំ ២០២៣ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២៣តទៅបានដោយរលូន។

ជាបន្តបន្ទាប់សមាជិកក្រុមប្រឹក្សាឃុំទាំងអស់បានពិនិត្យ យ៉ាងល្អិតល្អន់ហើយបានធ្វើការបោះឆ្នោតអនុម័ត ដោយសំលេងភាគច្រើនដាច់ខាត ក្នុងសំលេងឆ្នោតគាំទ្រ ៩ លើ ៩ ក្នុងចំនួនសមាជិកដែលបានចូលរួម ។

## ឧបសម្ព័ន្ធទី២





















មណ្ឌលសុខភាពបារាយណ៍
BARAY HEALTH CENTER

